# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 08-Oct-2019, 15:00
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## សំណើរបស់លោក ខៀវ សំផន សុំឲ្យទទួលយកភស្តុតាងបន្ថែម

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

**ជំនួយការ៖**

លោកស្រី សេង សុជាតា

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រីម

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele Mwachande MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

កញ្ញា Marie CAPOTORTO

កញ្ញា Cécile ROUBEIX

កញ្ញា Dounia HATTABI

លោក Stéphane NICOLAÏ

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានប្រកាសថា លោក ខៀវ សំផន ជាប់ពិរុទ្ធពីបទប្រល័យពូជសាសន៍ (លើជនជាតិវៀតណាម) បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ហើយបានផ្តន្ទាទោស លោក ខៀវ សំផន ឱ្យជាប់ពន្ធនាគារអស់មួយជីវិត ("សាលក្រម")[1]។ អង្គជំនុំជម្រះបានបញ្ជាក់ថា ខ្លួននឹងជូនដំណឹងអំពីសំអាងហេតុពេញលេញនៃសាលក្រមជាលាយលក្ខណ៍អក្សរ "ក្នុងពេលសមស្រប"[2]។

២. នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ មេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី") បានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ហើយបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") ឱ្យធ្វើមោឃភាពសាលក្រម ដោយមូលហេតុវិការៈទម្រង់ និងគ្មានសំអាងហេតុ[3]។ នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ តុលាការកំពូលបានសម្រេចមិនទទួលយកបណ្តឹងសាទុក្ខនេះ[4]។

៣. នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ភាគីបានទទួលការជូនដំណឹងអំពីសំអាងហេតុពេញលេញនៃសាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ("សំអាងហេតុនៃសាលក្រម")[5]។

៤. នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ មេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបានរកឃើញកំហុសរបស់អង្គជំនុំជម្រះ យ៉ាងហោចណាស់ ចំនួន ១៨២៤[6]។

---

[1] ប្រតិចារឹកសវនាការ ("ប្រតិចារឹក") ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/529.1** ទំព័រ ៣៨-៤២ ចន្លោះពីម៉ោង ១១:២៨ ដល់ម៉ោង ១១:៣៨។

[2] ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E1/529.1** ទំព័រ ៣ ប្រហែលម៉ោង ៩:៣៦។

[3] បណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ប្រឆាំងនឹងសាលក្រម ប្រកាសនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E463/1**។

[4] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់លោក ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសង្ខេបនៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ **E463/1/3**។

[5] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ (ជូនដំណឹងថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩) ឯកសារ **E465**។

៥. តាមរយៈសារណានេះ មេធាវីការពារក្តីស្នើសុំតុលាការកំពូលឲ្យទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ("កំណត់ហេតុ") ឯក ហេន និង ជួន ធី ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ និងត្រូវបានស្តាប់ចម្លើយ នៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤។ ដោយសារតែមានភាពមិនស៊ីសង្វាក់គ្នាច្រើន ដែលបានរកឃើញកាលពីពេលកន្លងទៅ រវាងចម្លើយរបស់សាក្សីឆ្លើយជូនអ្នកស៊ើបអង្កេត និងចម្លើយកត់ត្រានៅក្នុងកំណត់ហេតុ មេធាវីការពារក្តីក៏ស្នើសុំផងដែរឲ្យដាក់បង្ហាញខ្សែអាត់ថតសំឡេងនៃការស្តាប់ចម្លើយ ឯក ហេន និង ជួន ធី។ ដើម្បីចៀសវាងធ្វើសំណើជាលើកទីពីរទៀត មេធាវីការពារក្តីស្នើសុំតុលាការកំពូលឲ្យទទួលយកខ្សែអាត់ថតសំឡេងទាំងពីរនេះ ក្នុងពេលជាមួយគ្នាតែម្តង។

៦. យោងតាមច្បាប់ជាធរមាន (១) ភស្តុតាងមិនអាចរកបានក្នុងពេលសវនាការ (២) ភស្តុតាងអាចជាកត្តាកំណត់នាំឲ្យឈានដល់ការធ្វើសេចក្តីសម្រេច (៣) និងមិនស្ថិតនៅក្រោមមូលហេតុទូទៅនៃភាពមិនអាចទទួលយកបាន (៤)។

## ១. ច្បាប់ជាធរមាន

៧. នៅក្នុងក្របខ័ណ្ឌគតិយុត្តិនៃ អ.វ.ត.ក ការទទួលយកភស្តុតាងថ្មី នៅដំណាក់កាលបណ្តឹងសាទុក្ខត្រូវបានគ្រប់គ្រងដោយវិធាន ១០៤(១) និងវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង។ អនុលោមតាមវិធាន ១០៤(១) តុលាការកំពូលខ្លួនឯង "អាចបើកការពិនិត្យលើភស្តុតាង និងស្វែងរកភស្តុតាងថ្មី"។ វិធាន ១០៨(៧) ចែងថា៖

"ភាគីអាចស្នើសុំបន្ថែមភស្តុតាងចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល យោងតាមវិធាន ៨៧(៣) បើសិនជាភស្តុតាងនោះមិនអាចរកបានក្នុងពេលសវនាការ ហើយដែលអាចជាកត្តាកំណត់នាំឲ្យឈានដល់ការធ្វើសេចក្តីសម្រេចនៅក្នុងសវនាការ។ សេចក្តីស្នើសុំបន្ថែមភស្តុតាងត្រូវបញ្ជាក់ឲ្យ

[6] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1**។

បានច្បាស់លាស់អំពីទំនាក់ទំនងដោយផ្ទាល់ រវាងភស្តុតាងបន្ថែមថ្មីនោះជាមួយនឹងសំអាងហេតុជាក់លាក់ ដែលអង្គជំនុំជម្រះសាលាដំបូងបានលើក”។

៨. នៅក្នុងសាលដីកាលើសំណុំរឿង ០០២/០១ តុលាការកំពូលបានបញ្ជាក់ថា៖

“ដើម្បីបញ្ជាក់ថា ភស្តុតាងបន្ថែមដែលបានស្នើឡើងនោះ អាចជាកត្តាឈានទៅរកការធ្វើសេចក្តីសម្រេចបាន ភាគីដែលស្នើសុំភស្តុតាងត្រូវតែបង្ហាញថា ភស្តុតាងនេះ ប្រសិនបើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អាចនាំឱ្យអង្គជំនុំជម្រះនេះធ្វើការសម្រេចពីពិរុទ្ធភាពខុសប្លែកពីមុនទាំងស្រុង ឬផ្នែកខ្លះ។ ក្នុងការវាយតម្លៃបែបនេះ ភស្តុតាងបន្ថែមដែលបានស្នើឡើង ត្រូវតែបានវាយតម្លៃទៅតាមបរិបទនៃភស្តុតាង ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងការយល់ឃើញផ្នែកអង្គហេតុ ដែលមានលក្ខណៈសំខាន់ ឬចាំបាច់បំផុត ចំពោះការសម្រេចដាក់ពិរុទ្ធភាព ឬការប្រកាសទោស។ អាស្រ័យលើភាគីដែលស្នើសុំដាក់ភស្តុតាងបន្ថែម ក្នុងការបង្ហាញពីឥទ្ធិពលរបស់ភស្តុតាងដែលបានស្នើសុំដាក់បន្ថែមនោះ”[7]។

## ២. ភស្តុតាងមិនអាចរកបានក្នុងពេលសវនាការ

៩. សវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០១ បានបញ្ចប់ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។ ភាគីបានដាក់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល នៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ ហើយសវនាការបញ្ចប់កិច្ចពិភាក្សាដេញដោលបានប្រព្រឹត្តទៅ ពីថ្ងៃទី១៣ ដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧។ នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨ ខណៈដែលអង្គជំនុំជម្រះបានដកខ្លួនទៅពិភាក្សាសម្រេចអស់រយៈពេលជាងមួយឆ្នាំទៅហើយ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បង្ហាញឯកសារចំនួន ៨ មកពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤[8]។ ក្នុងចំណោមឯកសារទាំងនេះ មាន

[7] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **F36** កថាខណ្ឌ ៣០។

[8] ការស្នើសុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ **E319/71**។

កំណត់ហេតុរបស់សាក្សី ឯក ហេន ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ និងកំណត់ហេតុរបស់សាក្សី ជួន ធី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧[9]។

១០. ភាពយឺតយ៉ាវនេះបង្ហាញឲ្យឃើញអំពីកង្វះភាពខ្នះខ្នែងយ៉ាងច្បាស់ក្រឡែតរបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ សហព្រះរាជអាជ្ញាអន្តរជាតិគួរតែដាក់បង្ហាញឯកសារទាំងនេះឲ្យបានឆាប់បំផុត តាំងពីពេលខ្លួនបានដឹងមកម៉្លេះ ពីព្រោះនេះជាឯកសារពាក់ព័ន្ធនឹងសាក្សីដែលបានមកផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះ[10]។ ជាក់ស្តែង សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការដាក់បង្ហាញភ័ស្តុតាងដោះបន្ទុក ឲ្យបានឆាប់បំផុតនោះទេ[11]។

១១. កំហុសនេះមិនអាចទទួលយកបានទេ ពីព្រោះសហព្រះរាជអាជ្ញាអន្តរជាតិបានពន្លិចមេធាវីការពារក្តីឲ្យលិចលង់ក្នុងគំនរភ័ស្តុតាងដាក់បន្ទុកថ្មីៗមកពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ដែលខ្លួនចេះតែបន្តដាក់បញ្ចូលមិនឈប់ឈរ ពេញមួយអំឡុងពេលជំនុំជម្រះក្តី[12]។ ផ្ទុយទៅវិញ ពេលត្រូវជំទាស់តវ៉ាអំពីភាពអាចជឿជាក់បានរបស់សាក្សីដាក់បន្ទុក ដូចជា ឯក ហេន ឬពេលត្រូវបញ្ជាក់

[9] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ ឯកសារ **E319/71.2.7**, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ធី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ **E319/71.2.4**។

[10] ការស្នើសុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ **E319/71** កថាខណ្ឌ ១។ សូមមើលផងដែរ ការស្នើសុំដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ របស់សហព្រះរាជអាជ្ញាអន្តរជាតិ - ឧបសម្ព័ន្ធ ក ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨ ឯកសារ **E319/71.2**។

[11] វិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង៖ "ក្នុងរយៈពេលឆាប់ដែលអាចធ្វើទៅបាន សហព្រះរាជអាជ្ញាត្រូវបង្ហាញទៅសហចៅក្រមស៊ើបអង្កេតនូវសម្ភារៈទាំងឡាយដែលសហព្រះរាជអាជ្ញាបានដឹង ហើយដែលសម្ភារៈទាំងនេះនឹងអាចនាំឲ្យគ្មានពិរុទ្ធភាព ឬសម្រាលពិរុទ្ធភាពនៃជនសង្ស័យ ឬជនត្រូវចោទ ឬធ្វើឲ្យប៉ះពាល់ដល់ភាពជឿជាក់នៃភ័ស្តុតាងក្នុងការចោទប្រកាន់"។ អង្គជំនុំជម្រះបានបញ្ជាក់ថា វិធាននេះអាចយកមកអនុវត្តចំពោះមុខអង្គជំនុំជម្រះបាន៖ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ឯកសារ **E363/3** កថាខណ្ឌ ១៦ កថាខណ្ឌ ២០។ សូមមើលផងដែរ អំពីកាតព្វកិច្ចនៃការដាក់បង្ហាញ៖ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ឯកសារ **E363/3** កថាខណ្ឌ ៣១។ សេចក្តីសម្រេចលើសំណើសុំស្តីពីកាលបរិច្ឆេទកំណត់ តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ **E421/4** កថាខណ្ឌ ៩។

[12] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់លោក ខៀវ សំផន (០០២/០២) ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ ឯកសារ **E457/6/4** កថាខណ្ឌ ៦៦០ ដល់កថាខណ្ឌ ៦៦៥។

អំពីភាពអាចជឿជាក់បានរបស់សាក្សីដោះបន្ទុក ដូចជា ជួន ធី ជាដើម ដែលបានដកស្រង់យ៉ាងសន្ធឹកសន្ធាប់ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន[13] សហព្រះរាជអាជ្ញាអន្តរជាតិមិនប្រញាប់ប្រញាល់ ក្នុងការដាក់បង្ហាញភ័ស្តុតាងជូនដល់ភាគីទេ។ ប្រសិនបើសហព្រះរាជអាជ្ញាអន្តរជាតិបានខ្នះខ្នែងនោះ មេធាវីការពារក្តីអាចស្នើសុំឲ្យទទួលយកឯកសារទាំងនេះរួចទៅហើយ មុនពេលបិទបញ្ចប់កិច្ចពិភាក្សាដេញដោលនៅសាលាដំបូង។

១២. អង្គជំនុំជម្រះក៏ខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនផងដែរ ដោយមិនបើកកិច្ចពិភាក្សាដេញដោលឡើងវិញ ទាំងដឹងថា ឯកសារទាំងនេះបានមកពីសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានមកផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះ[14]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះបានរម្លឹកជារឿយៗអំពីការអនុវត្តរបស់ខ្លួន ក្នុងការទទួលយកជាភ័ស្តុតាង ដើម្បីជាប្រយោជន៍យុត្តិធម៌ នូវចម្លើយពីមុន និងពេលក្រោយរបស់សាក្សីដែលបានមកផ្តល់សក្ខីកម្ម[15]។ បើតាមពាក្យពេចន៍របស់អង្គជំនុំជម្រះផ្ទាល់តែម្តង ការអនុវត្តនេះប្រើប្រាស់ "ដើម្បីអាចឲ្យអង្គជំនុំជម្រះ និងភាគី វាយតម្លៃបានពេញលេញពីភាពអាចជឿជាក់បាន ស្របតាមកម្រិតសង្គតភាពនៃចម្លើយរបស់សាក្សី" ដើម្បី"ជាប្រយោជន៍នៃការស្វែងរកការពិត"[16]។

---

[13] សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០១៧ ឯកសារ **E457/6/1** (ឯក ហេន ត្រូវបានស្រង់សម្តីនៅក្នុង ១៦ កំណត់សម្គាល់ជើងទំព័រផ្សេងៗគ្នា និង ជួន ធី តែ ៨ ដងប៉ុណ្ណោះ ហើយសុទ្ធតែជាភ័ស្តុតាងដាក់បន្ទុក)។

[14] អនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូងទៅកាន់ការិយាល័យចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០១៨ ឯកសារ **E319/71/1**។

[15] ការទទួលយកកំណត់ហេតុស្តាប់ចម្លើយដែលបានដាក់បង្ហាញថ្មីៗពីសំណុំរឿង ០០៣ និង ០០៤ របស់សាក្សីដែលបានផ្តល់សក្ខីកម្មក្នុងអំឡុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ ឯកសារ **E319/68/1** កថាខណ្ឌ ២, ការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយដែលបានដាក់បង្ហាញថ្មីៗ ពីក្នុងសំណុំរឿង ០០៤ របស់សាក្សីដែលបានផ្តល់សក្ខីកម្មនៅក្នុងអំឡុងកិច្ចដំណើរការនៃនីតិវិធីជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ឯកសារ **E319/69** កថាខណ្ឌ ២, ការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយដែលបានដាក់បង្ហាញនាពេលថ្មីៗ ពីក្នុងសំណុំរឿង ០០៣ និង ០០៤ របស់សាក្សីដែលបានផ្តល់សក្ខីកម្មនៅក្នុងអំឡុងពេលកិច្ចដំណើរការនៃនីតិវិធីនៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ឯកសារ **E319/67** កថាខណ្ឌ ២ និងកថាខណ្ឌ ៤។

[16] ដូចយោងខាងលើ។ សូមមើលផងដែរ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ **E363/3** កថាខណ្ឌ ២៥។

១៣. ដោយមិនខ្វល់ពីយុត្តិសាស្ត្រផ្ទាល់របស់ខ្លួន អង្គជំនុំជម្រះបានត្រឹមតែសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេតឲ្យដាក់បង្ហាញឯកសារ ដើម្បីឲ្យភាគីអាចចូលពិនិត្យមើលបាន ទាំងខ្លួនដឹងថាភាគីនឹងមិនអាចពិភាក្សាដេញដោលលើឯកសារទាំងនោះបាន។ ជាក់ស្តែង យោងតាមវិធាន ៩៦(២) នៃវិធានផ្ទៃក្នុង ភាគីមិនអាចដាក់សេចក្តីសន្និដ្ឋានណាមួយបានទេ ក្នុងពេលអង្គជំនុំជម្រះកំពុងពិភាក្សាសម្រេច ហើយមានតែអង្គជំនុំជម្រះប៉ុណ្ណោះដែលអាចបើកកិច្ចពិភាក្សាដេញដោលឡើងវិញបាន[17]។ ដូច្នេះ ដោយមិនបើកនីតិវិធីឡើងវិញ អង្គជំនុំជម្រះបានរារាំងមេធាវីការពារក្តីមិនឲ្យពិភាក្សាដេញដោល ចំពោះមុខខ្លួន លើខ្លឹមសារនៃចម្លើយដោះបន្ទុក ឬភាពអាចជឿជាក់បានរបស់សាក្សីមួយចំនួនដែលត្រូវបានយកមកប្រើប្រាស់ដើម្បីដាក់បន្ទុកលើលោក ខៀវ សំផន។

១៤. មេធាវីការពារក្តីមិនអាចហាមចិត្តខ្លួនឯងមិនឲ្យគិតថា នេះគឺជាចេតនារបស់អង្គជំនុំជម្រះ បានទេ។ នៅដំណាក់កាលពិភាក្សាសម្រេច និងសរសេរសាលក្រម អង្គជំនុំជម្រះបានដឹងច្បាស់ថា ខ្លួននឹងប្រើប្រាស់សក្ខីកម្មរបស់សាក្សីទាំងនេះ។ សំអាងហេតុនៃសាលក្រមបង្ហាញឲ្យឃើញថា ឯក ហេន ជាសាក្សីសំខាន់ ដែលអង្គជំនុំជម្រះបានប្រើប្រាស់ ដើម្បីផ្តន្ទាទោសលោក ខៀវ សំផន។ ឯចម្លើយដោះបន្ទុករបស់ ជួន ធី មិនត្រូវបានគេអើពើ ឬប្រើប្រាស់ដោយផ្នែកសម្រាប់តែដាក់បន្ទុកប៉ុណ្ណោះ។ នៅចំពោះមុខភស្តុតាងថ្មីទាំងនេះ និងផលប៉ះពាល់លើការពិនិត្យភាពអាចជឿជាក់បានរបស់សាក្សីចៅក្រមវិជ្ជាជីវៈ និងប្រកបដោយអនាគតិ គួរណាតែបើកកិច្ចពិភាក្សាដេញដោលឡើងវិញ ដើម្បីស្តាប់ទឡ្ហីករណ៍របស់ភាគី រួចយកទៅពិចារណាក្នុងពេលពិភាក្សាសម្រេច។ ប៉ុន្តែ តុលាការកំពូលបានរម្លឹកថា "ខាងទិដ្ឋភាពនៃការអនុវត្តជាក់ស្តែង តុលាការគួរបើកកិច្ចដំណើរការនីតិវិធីឡើងវិញនៅពេលខ្លួនរកឃើញថា បញ្ហាពាក់ព័ន្ធនឹងលទ្ធផលនៃការពិភាក្សាសម្រេចតម្រូវឲ្យធ្វើដូច្នេះ"[18]។ ដោយមិនព្រមបើកកិច្ចពិភាក្សាដេញដោលឡើងវិញ អង្គជំនុំជម្រះបានបង្ហាញអំពីឆន្ទៈក្នុងការផ្តន្ទាទោសលោក ខៀវ សំផន ឲ្យខាងតែបាន។ ដោយមើលឃើញពីការរំលោភបំពានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងអង្គជំនុំជម្រះ មេធាវីការពារក្តីគ្មានជម្រើសអ្វីផ្សេងក្រៅពីស្នើសុំនៅដំណាក់កាល

---

[17] វិធាន ៩៦(២) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក៖ "គ្មានពាក្យសុំណាមួយអាចត្រូវបានលើកយកមកសំអាងទៀតទេនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងគ្មានសេចក្តីសន្និដ្ឋានណាមួយអាចទទួលយកបានទៀតឡើយ។ អំឡុងពេលពិភាក្សាសម្រេចចៅក្រមអាចបើកនីតិវិធីឡើងវិញបាន"។

[18] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ **E284/2/1/2** កថាខណ្ឌ ៨។

បណ្តឹងសាទុក្ខឲ្យទទួលយកភស្តុតាងទាំងនេះ ដែលអាចជាកត្តាកំណត់នាំឲ្យឈានដល់ការធ្វើសេចក្តីសម្រេច។

## ៣. ការបង្ហាញភស្តុតាងថ្មីក្នុងពេលជំនុំជម្រះក្តីអាចជាកត្តាកំណត់នាំឲ្យឈានដល់ការធ្វើសេចក្តីសម្រេច

១៥. កំណត់ហេតុថ្មីរបស់ ឯក ហេន រឹតតែបញ្ជាក់អំពីកង្វះភាពអាចជឿជាក់បាន ខណៈដែលសក្ខីកម្មរបស់គាត់ត្រូវបានអង្គជំនុំជម្រះយកមកប្រើប្រាស់ ជាច្រើនលើកច្រើនសា សម្រាប់ជាមូលដ្ឋាននៃការផ្តន្ទាទោសលោក ខៀវ សំផន (៣.១)។ ផ្ទុយទៅវិញ កំណត់ហេតុរបស់ ជួន ធី រឹតតែបញ្ជាក់អំពីភាពអាចជឿជាក់បាននៃភស្តុតាងដោះបន្ទុកនៃសក្ខីកម្មរបស់គាត់ ដែលអង្គជំនុំជម្រះមានចេតនាធ្វើមិនដឹងមិនឮ (៣.២)។

### ៣.១. កំណត់ហេតុថ្មីរបស់ ឯក ហេន

១៦. ឯក ហេន ត្រូវបានអង្គជំនុំជម្រះចាត់ទុកជាសាក្សីសំខាន់គួរឲ្យជឿជាក់បាន។ សក្ខីកម្មរបស់គាត់ត្រូវបានដកស្រង់ យ៉ាងហោចណាស់ ៩ ដង នៅក្នុងសំអាងហេតុនៃសាលក្រម ពាក់ព័ន្ធនឹងវគ្គរៀនសូត្រនយោបាយ ដែលលោក ខៀវ សំផន ជាអ្នកឧទ្ទេសនាម នៅបុរីកីឡា[19]។ អង្គហេតុនេះជាកត្តាកំណត់ សម្រាប់ផ្តន្ទាទោសលោក ខៀវ សំផន ដោយហេតុថាអង្គជំនុំជម្រះបានផ្អែកលើភស្តុតាងនេះ ដើម្បីទាញសេចក្តីសន្និដ្ឋានលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់លោក ខៀវ សំផន (៣.១.១) ការរៀបចំ និងការអនុវត្តគោលបំណងរួម (៣.១.២) និងតួនាទីតាមសន្ទតរបស់ម្ចាស់បណ្តឹងសាទុក្ខ (៣.១.៣)។ ក៏ប៉ុន្តែ ដោយសារមានភាពផ្ទុយគ្នាច្រើននៅក្នុងចម្លើយរបស់សាក្សី ដែលត្រូវបាន

---

[19] សាលក្រមសំណុំរឿង 00២/0២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៦0៧ (ផ្នែកទី ៨៖ តួនាទី និងមុខងាររបស់ ខៀវ សំផន) កថាខណ្ឌ ៣២១៦ (ផ្នែកទី ១៣៖ ការប្រព្រឹត្តិចំពោះក្រុមគោលដៅ - ជនជាតិចាម) កថាខណ្ឌ ៣៣៩0 និងកថាខណ្ឌ ៣៤០៤ (ផ្នែកទី ១៣៖ ការប្រព្រឹត្តិចំពោះក្រុមគោលដៅ - ជនជាតិវៀតណាម) កថាខណ្ឌ ៣៧៣៩ និងកថាខណ្ឌ ៣៩១៦ (ផ្នែកទី ១៦៖ គោលបំណងរួម) កថាខណ្ឌ ៤២៥៣ កថាខណ្ឌ ៤២៧១ និងកថាខណ្ឌ ៤២៧២ (ផ្នែកទី ១៨៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន)។

លើកឡើងរួចមកហើយក្នុងសំណុំរឿង ០០២/០១[20] និងត្រូវបានបញ្ជាក់អះអាងដោយកំណត់ហេតុថ្មី ច្បាស់ណាស់ថាអង្គជំនុំជម្រះមិនអាចផ្អែកលើសក្ខីកម្មរបស់ ឯក ហេន បានទេ[21]។

### ៣.១.១. សារៈសំខាន់នៃចម្លើយរបស់ ឯក ហេន លើការកំណត់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់លោក ខៀវ សំផន

១៧. អង្គជំនុំជម្រះបានប្រើប្រាស់សក្ខីកម្មរបស់ ឯក ហេន ដើម្បីទាញសេចក្តីសន្និដ្ឋានអំពីចេតនារបស់លោក ខៀវ សំផន ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស (៣.១.១.១) ការចូលរួមចំណែករបស់គាត់ ក្នុងសហឧក្រិដ្ឋកម្មរួម (៣.១.១.២) និងការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្ម ក្រោយហេតុការណ៍កើតឡើង (៣.១.១.៣)។

#### ៣.១.១.១. ចេតនារបស់លោក ខៀវ សំផន ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស

១៨. ដើម្បីសន្និដ្ឋានថា លោក ខៀវ សំផន មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅមន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល អង្គជំនុំជម្រះបានផ្អែកលើអង្គហេតុដែលបង្ហាញថា លោក ខៀវ សំផន "បានដឹង និងគាំទ្រឲ្យមានការចាប់ខ្លួនមេដឹកនាំសំខាន់ៗរបស់បក្ស"[22]។

១៩. ជាបឋម សូមបញ្ជាក់ថា ការដឹងតាមការសន្មតរបស់លោក ខៀវ សំផន អំពីការចាប់ខ្លួនទាំងនេះ មិនអាចយកមកធ្វើជាភ័ស្តុតាងថាគាត់បានដឹងអំពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នោះឡើយ។ ជាពិសេស អង្គជំនុំជម្រះមិនពន្យល់ថា ហេតុអ្វី ឬហេតុដូចម្តេចបានជាលោក ខៀវ សំផន មាន

---

[20] សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ F17 កថាខណ្ឌ ៥៣២។

[21] សូមមើលឧបសម្ព័ន្ធ៖ សេចក្តីអះអាងរបស់លោក ឯក ហេន ស្តីពីវគ្គសិក្សាដែលបង្រៀនដោយ នួន ជា និង ខៀវ សំផន នៅបុរីកីឡា ("ឧបសម្ព័ន្ធ")។

[22] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤២៨៤។

ចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និង អំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការប៉ះពាល់លើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការ ប្រព្រឹត្តិដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ នៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ មនុស្ស ជាកម្មវត្ថុនៃសំណុំរឿង ០០២/០២។ ជាក់ស្តែង ការយល់ឃើញថា ការបោសសម្អាត "មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាមួយគោលនយោបាយក្នុងការបង្កើត និងប្រតិបត្តិការមន្ទីរសន្តិ សុខ និងកន្លែងសម្លាប់មនុស្ស"[23] មិនអាចឲ្យអង្គជំនុំជម្រះរួចផុតពីការកំណត់អំពីចេតនាផ្ទាល់របស់ លោក ខៀវ សំផន ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ បានឡើយ។ ដូច្នេះ ការទាញសេចក្តីសន្និដ្ឋាន អំពីចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម ចេញពីការគ្រាន់តែដឹង ឬឯកភាពឲ្យចាប់ខ្លួន ប៉ង់ មិនមែនជាការ សន្និដ្ឋានសមហេតុផលនោះទេ ជាពិសេស នៅពេលភ័ស្តុតាងគាំទ្រដល់ការសន្និដ្ឋាននេះមានភាពទន់ ខ្សោយ។

២០. តាមពិត អង្គជំនុំជម្រះមិនគួរណាបង្ហាញថាលោក ខៀវ សំផន បានដឹង និងគាំទ្រឲ្យចាប់ខ្លួន ប៉ង់ ដោយគ្រាន់តែផ្អែកលើចម្លើយរបស់ ឯក ហេន ប៉ុណ្ណឹងទេ[24]។ យ៉ាងណាមិញ នៅកថាខណ្ឌ ៤២៧២ នៃសំអាងហេតុនៃសាលក្រម អង្គជំនុំជម្រះអះអាងថា៖

"នៅពាក់កណ្តាលឆ្នាំ១៩៧៨ ខៀវ សំផន បានធ្វើជាអធិបតីក្នុងកិច្ចប្រជុំអប់រំនយោបាយនៅបុរីកីឡា ជាកន្លែងដែលគាត់បានប្រកាសនៅចំពោះមុខអ្នកចូលរួម ពី ៤០០ ទៅ ៥០០ នាក់ថា ឈ្មោះ ឈឹម សំអោក ហៅ ប៉ង់ នៅមន្ទីរ ស-២១ ត្រូវបានចាប់ខ្លួន និងដកចេញ ដោយសារតែគាត់ជាអ្នកចូលដៃ ក្បត់ជាមួយនឹងយួន និងបានណែនាំថាកុំឲ្យធ្វើតាមអ្វីដែល ប៉ង់ បានធ្វើ"។

[23] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤២៨៤។

[24] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤២៨៤ កំណត់សម្គាល់ជើងទំព័រ លេខ ១៣៩៨៦ "សូមមើល ខាងក្រោម កថាខណ្ឌ ៤២៧២"។ កំហុសដែលបានលើកឡើងនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ E465/4/1 កថាខណ្ឌ ៣២ កំហុស ១៨.២០៥, ១៨.២០៦, ១៨.២០៧ និង ១៨.២០៨។

២១. បើតាមអង្គជំនុំជម្រះ សក្ខីកម្មរបស់ ឯក ហេន ក្នុងសវនាការ ស៊ីសង្វាក់គ្នានឹងកំណត់ហេតុរបស់គាត់ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨[25]។ ពិតមែនតែនៅពេលសហព្រះរាជអាជ្ញាសួរដេញដោល ឯក ហេន បានបញ្ជាក់អះអាងទៅលើខ្លឹមសារមួយផ្នែកធំនៃកំណត់ហេតុរបស់គាត់ ប៉ុន្តែ គាត់បានកំណត់ថា វគ្គរៀនសូត្រដែលលោក ខៀវ សំផន ជាអ្នកបង្រៀន បានប្រព្រឹត្តទៅ នៅឆ្នាំ១៩៧៦ គឺមិនមែននៅពាក់កណ្តាលឆ្នាំ១៩៧៨ ទេ[26]។ ផ្ទុយទៅវិញ នៅឆ្នាំ១៩៧៦ លោក ខៀវ សំផន ទំនងជាមិនអាចនិយាយអំពីការចាប់ខ្លួន ប៉ង់ ទេ ពីព្រោះ បើតាមការសន្និដ្ឋានផ្ទាល់របស់អង្គជំនុំជម្រះ ប៉ង់ ត្រូវបានចាប់ខ្លួន នៅខែមេសា ឆ្នាំ១៩៧៨[27]។ ប៉ុន្តែ អង្គជំនុំជម្រះមិនខ្វល់ខ្វាយពីភាពផ្ទុយគ្នារបស់សាក្សីឡើយ នៅក្នុងសម្រង់ដែលខ្លួនបានដកស្រង់។ លើសពីនេះទៅទៀត ការពិចារណាលើចម្លើយទាំងមូលរបស់ ឯក ហេន បញ្ជាក់ថា ជារួម សាក្សីនេះខ្វះភាពអាចជឿជាក់បាន។

២២. ជាក់ស្តែង ក្នុងកំណត់ហេតុ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨ និងនៅដើមដំបូងនៃការសួរដេញដោលក្នុងសវនាការ ឯក ហេន បាននិយាយអំពីវគ្គរៀនសូត្រនយោបាយលើកទីមួយ ដែលបានធ្វើឡើងក្នុងឆ្នាំ១៩៧៦ នៅបុរីកីឡា ជាមួយលោក ខៀវ សំផន[28] និងលើកទីពីរ ក្នុងឆ្នាំ១៩៧៨ ជាមួយលោក នួន ជា[29]។ សាក្សីបានផ្លាស់ប្តូរចម្លើយរបស់ខ្លួនទាំងស្រុង ពេលមេធាវីការពារក្តីសួរដេញដោល។ មុនដំបូង គាត់បានអះអាងថា វគ្គរៀនសូត្រនយោបាយលើកទីមួយ នៅបុរីកីឡា ត្រូវបានបង្រៀនដោយលោក ខៀវ សំផន "នៅចុងឆ្នាំ១៩៧៦" ក្រោយជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[30]។ ប៉ុន្តែ ក្រោយមកទៀត គាត់បានឆ្លើយ និងរក្សាចម្លើយនេះរហូតដល់ចប់សក្ខីកម្មថា

---

[25] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** ជើងទំព័រ ១៣៩៤៦។

[26] ប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** ទំព័រ ៤០ ដល់ ៤៣ និងទំព័រ ៤៥ ដល់ ៤៨, កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨ ឯកសារ **E3/474** ERN 00172064។

[27] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៣៩០ កំណត់សម្គាល់ជើងទំព័រលេខ ១១៤៣៧។

[28] ប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** ម៉ោង [11:15:09]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨ ឯកសារ **E3/474** ERN 00172064។

[29] ប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** ម៉ោង [11:38:54]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨ ឯកសារ **E3/474** ERN 00172064។

[30] ប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** ពីម៉ោង [14:12:13] ដល់ម៉ោង [14:09:40]។

លោក នួន ជា ដឹកនាំវគ្គរៀនសូត្រលើកទីមួយ នៅឆ្នាំ១៩៧៦ ឯលោក ខៀវ សំផន ដឹកនាំវគ្គរៀនសូត្រលើកទីពីរ នៅឆ្នាំ១៩៧៨[31]។

២៣. ចៅក្រមមានវិចារណញ្ញាណគ្រប់រូបគួរណាតែយកចិត្តទុកដាក់ដល់ការប្រែក្រឡាស់នេះ។ នៅពេលសួរអំពីភាពផ្ទុយគ្នានេះ ឯក ហេន បានពន្យល់ ៨ លើក ថា គាត់ភាន់ច្រឡំ ឯការចងចាំរបស់គាត់មិនល្អដូចពីមុនទេ ហើយព័ត៌មាននេះត្រូវបានអង្គជំនុំជម្រះបំភ្លេចចោលទាំងស្រុង៖

"គ្រាន់ថាវាយូរហើយ ដូចជានិយាយរួម ការភ្លេចភ្លាំងខ្លះដែរ មិនមែនថាមិនភ្លេចទេ ព្រោះវាយូរហើយ។ ព្រោះតាំងពីក្មេងរហូតដល់ចំណាស់នេះហើយ វាអាចភ្លេចភ្លាំងខ្លះ។ ដូច្នេះ សំណួរមានតែពីរហ្នឹង គ្រាន់ថាច្រឡំមនុស្សអីក៏ថាអ៊ីចឹងទៅចុះ ប៉ុន្តែ មានតែពីរហ្នឹងទេ ធ្លាប់ទៅរៀនសូត្រជាមួយគាត់ ចាស"[32]។

"បើនិយាយទៅវាយូរដែរហើយ។ ការចងចាំក៏មានការភ្លេចភ្លាំងខ្លះ ចាស"[33]។

"ដូច្នេះការពាក់ព័ន្ធច្រឡំគ្នា ដូច្នេះវា បើនិយាយទៅវាយូរមកហើយ វាអាចភាន់ច្រឡំខ្លះដែរ មិនមែនថាមិនភាន់ច្រឡំទេ"[34]។

"ការរៀន គឺមានរៀនពិតមែន គ្រាន់តែថាវាយល់ច្រឡំទាំងពីរហ្នឹង"[35]។

"កន្លែងណាខ្ញុំចាំ គឺខ្ញុំឆ្លើយ កន្លែងណាមិនចាំ គឺខ្ញុំមិនបានឆ្លើយ។ ដូច្នេះ ការចងចាំមិនបាន គឺចាត់

---

[31] ប្រតិចារឹក ថ្ងៃទី0៣ ខែកក្កដា ឆ្នាំ២0១៣ ឯកសារ **E1/217.1** ពីម៉ោង [14:09:40] ដល់ម៉ោង [14:16:00] និងពីម៉ោង [15:04:43] ដល់ម៉ោង [15:09:26]។

[32] ប្រតិចារឹក ថ្ងៃទី0៣ ខែ កក្កដា ឆ្នាំ២0១៣ ឯកសារ **E1/217.1** មុនម៉ោង [14:14:17]។

[33] ប្រតិចារឹក ថ្ងៃទី0៣ ខែ កក្កដា ឆ្នាំ២0១៣ ឯកសារ **E1/217.1** មុនម៉ោង [14:42:32]។

[34] ប្រតិចារឹក ថ្ងៃទី0៣ ខែ កក្កដា ឆ្នាំ២0១៣ ឯកសារ **E1/217.1** ក្រោយម៉ោង [15:04:43]។

[35] ប្រតិចារឹក ថ្ងៃទី0៣ ខែកក្កដា ឆ្នាំ២0១៣ ឯកសារ **E1/217.1** ម៉ោង [15:08:12]។

ទុកថាខ្ញុំអត់បានដឹង។ ព្រោះវាអត់ចាំ វាកន្លងយូរឆ្នាំហើយ ដូចឃើញស្រាប់ហើយ”[36]។

“លោកថាអ៊ីចឹងក៏ថាបាន ព្រោះសម័យនោះមកដល់បច្ចុប្បន្នមិនមែនច្បាស់ដូចថ្មីៗនេះឯណា ជំនាន់ពីក្មេងមកដល់សម័យនេះ អាយុជិតផុតទៅវិញទៅហើយ។ បានន័យថាការចងចាំ ក៏វាមានអន់ថយទៅដែរ”[37]។

“អារឿងកន្លងហួសទៅហើយ វាមិនអាចចាំដូចថ្មីៗទេ ចាស”[38]។

“កាលនោះ វានៅច្បាស់ តែឥឡូវ វាមិនទាន់ច្បាស់ទេ វាអាចចង់ភ្លេចភ្លាំងអស់ទៅហើយ។ អាយុកាន់តែច្រើនហើយ ចូល ៦០ ស្អែកៗទៅហើយ ចាំស្អីទៀត មើលអក្សរមិនច្បាស់ផង”[39]។

២៤. បញ្ហានៃការចងចាំទាំងនេះត្រូវបានបញ្ជាក់អះអាង នៅក្នុងកំណត់ហេតុថ្មី ដែលត្រូវបានស្នើសុំដាក់ជាភស្តុតាង។ ជាក់ស្តែង ភាពផ្ទុយគ្នាថ្មីៗបានលេចឡើង។ ម្តងនេះ ឯក ហេន បានឆ្លើយថាលោក ខៀវ សំផន បានដឹកនាំវគ្គរៀនសូត្រនយោបាយលើកទីមួយ នៅឆ្នាំ១៩៧៨[40] ហើយលោក នួន ជា បានដឹកនាំវគ្គរៀនសូត្រនយោបាយលើកទីពីរ នៅឆ្នាំ១៩៧៨ ដែរ[41]។ ប្រឈមនឹងការប្រែក្រឡាស់នេះ អ្នកស៊ើបអង្កេតបានសួរថា តើ ខៀវ សំផន មិនមែនបង្រៀននៅឆ្នាំ១៩៧៦ ទេឬ ដោយផ្អែកលើកំណត់ហេតុពីមុនរបស់គាត់ និងបំភ្លេចចោលនូវភាពផ្ទុយគ្នានៃប្រតិចារឹកសវនាការ។ ប៉ុន្តែ ឯក ហេន បានឆ្លើយថា គឺពិតជានៅឆ្នាំ១៩៧៨ មុនពេលវៀតណាមចូលលុកលុយបន្តិច[42]។ ជាក់ស្តែង នៅក្នុងកំណត់ហេតុថ្មីនេះ ឯក ហេន បានកំណត់ម្តងទៀតថា លោក ខៀវ សំផន គឺជាវាគ្មិន

[36] ប្រតិចារឹក ថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** មុនម៉ោង [15:17:55]។

[37] ប្រតិចារឹក ថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** មុនម៉ោង [15:26:09]។

[38] ប្រតិចារឹក ថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** មុនម៉ោង [15:26.09]។

[39] ប្រតិចារឹក ថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** ក្រោយម៉ោង [15:28:21]។

[40] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ ឯកសារ **E319/71.2.7** ស./ឆ. ៤៣, ៤៤, ៥៦ និង ៥៨។

[41] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ ឯកសារ **E319/71.2.7** ស./ឆ. ៥៥ និង ៥៦។

[42] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ ឯកសារ **E319/71.2.7** ស./ឆ. ៤៤។

នៅក្នុងវគ្គរៀនសូត្រលើកទីមួយ ប៉ុន្តែម្តងនេះ គឺនៅឆ្នាំ១៩៧៨។ មានន័យថា វគ្គរៀនសូត្រលើកទីពីរ ជាមួយ លោក នួន ជា ធ្វើឡើងក្រោយវគ្គរៀនសូត្រជាមួយលោក ខៀវ សំផន បន្តិច។ នេះជាអង្គហេតុមួយបែបទៀត ដែលចោទជាបញ្ហាជាថ្មីម្តងទៀតដល់ភាពអាចជឿជាក់បាននៃចម្លើយរបស់សាក្សី។

២៥. កំណត់ហេតុថ្មី ឆ្នាំ២០១៧ នេះ រឹតតែបញ្ជាក់ជាពិសេសថា ឯក ហេន ហាក់ដូចជាមិនអាចនឹកឃើញកាលបរិច្ឆេទនៃវគ្គរៀនសូត្រដែលគាត់បានចូលរួម និងមិនអាចចាំបានថាអ្នកណាជាវាគ្មិននៅក្នុងវគ្គរៀនសូត្រលើកទីមួយ ឬវគ្គរៀនសូត្រលើកទីពីរ។ គាត់ក៏មិនអាចចាំបានពីខ្លឹមសារនៃវគ្គរៀនសូត្រ។ ជាក់ស្តែង ការភាន់ច្រឡំកាលបរិច្ឆេទ និងវគ្គរៀនសូត្រ ធ្វើឱ្យយើងមិនអាចដឹងអំពីប្រធានបទ ដែលលោក ខៀវ សំផន និងលោក នួន ជា បាននិយាយ។

២៦. បើតាមចម្លើយឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រធានបទ ដូចជា ការលើកទឹកចិត្តឱ្យធ្វើការសីលធម៌រស់នៅ បញ្ហាពួកភូមិភាគបូព៌ា "ក្បត់" ត្រូវបានលើកឡើង ប៉ុន្តែ គ្មានការចង្អុលបង្ហាញឱ្យដឹងថា លោក ខៀវ សំផន ឬលោក នួន ជា ជាអ្នកនិយាយនោះទេ[43]។ ក្នុងកំណត់ហេតុ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨ ឯក ហេន បានអះអាងថា ក្នុងវគ្គរៀនសូត្រ នៅឆ្នាំ១៩៧៦ លោក ខៀវ សំផន បាននិយាយពីការខំធ្វើការ និងបានលើកឡើងអំពីករណីចាប់ខ្លួន ប៉ង់ ដែលមិនអាចទៅរួចឡើយ បើយោងតាមកាលបរិច្ឆេទ ដូចយើងបានឃើញខាងលើ[44]។ ផ្ទុយទៅវិញ បើតាមខ្សែអាត់ថតសំឡេងនៃការស្តាប់ចម្លើយនៅឆ្នាំ២០០៨ ក្នុងវគ្គរៀនសូត្រលើកទីមួយ គ្មានការនិយាយអំពីជនក្បត់ទាល់តែសោះ[45]៖ លោក នួន ជា បានលើកអំពីបញ្ហាពួកភូមិភាគឧត្តរក្បត់ និង កុយ ធួន ក្នុងវគ្គរៀនសូត្រលើកទីពីរ។ លោក នួន ជា ក៏បានអំពាវនាវឱ្យការពារទឹកដីកុំឱ្យយួនឈ្លានពាន[46]។

---

[43] កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឯក ហេន ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៣ ឯកសារ **E3/4635**, ERN 0019581, 0019586។

[44] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨ ឯកសារ **E3/474**, ERN 00172064។ សូមមើលផងដែរ កថាខណ្ឌ ២១ នៃសំណើនេះ។

[45] ខ្សែអាត់ថតសំឡេងនៃការស្តាប់ចម្លើយសាក្សី ឯក ហេន (**E3/474**) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨ ឯកសារ **D94/8R** លក្រោយម៉ោង [00.35.42]។

[46] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៨ ឯកសារ **E3/474**, ERN 00172064។

២៧. ក្នុងពេលផ្តល់សក្ខីកម្ម នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ ឯក ហេន បានបញ្ជាក់អះអាងថា លោក នួន ជា បានមកនិយាយអំពីការការពារទឹកដីប្រឆាំងនឹងការលុកលុយពីសំណាក់វៀតណាម និងបានលើកឡើងពីការក្បត់របស់ កុយ ធួន និងភូមិភាគឧត្តរ[47]។ គាត់បានអះអាងថា លោក ខៀវ សំផន និយាយតែរឿងការងារ ការតស៊ូខំប្រឹងធ្វើការឲ្យទាន់ផែនការ ការជួយធ្វើការគ្នា ដើម្បី "ស្តារសេដ្ឋកិច្ចប្រទេសជាតិ [ពីព្រោះ] យើងកំពុងរួចពីសង្គ្រាម"[48]។ គាត់ក៏បានរក្សាចម្លើយថា លោក ខៀវ សំផន បាននិយាយអំពីការចាប់ខ្លួន ប៉ង់ ទោះបីជាពេលវេលាមិនស៊ីសង្វាក់គ្នាក៏ដោយ[49]។ ផ្ទុយទៅវិញ ពេល ឯក ហេន បានផ្លាស់ប្តូរចម្លើយរបស់ខ្លួន ក្នុងពេលផ្តល់សក្ខីកម្ម គាត់បានសង្កត់ធ្ងន់ថា ក្នុងវគ្គរៀនសូត្រលើកទីមួយ ក្រោមអធិបតីភាពលោក នួន ជា គេនិយាយតែពីរឿងការងារប៉ុណ្ណោះ គឺមិនមាននិយាយអំពីជនក្បត់ទេ។ ក្នុងចម្លើយកែប្រែថ្មីនៅពេលសវនាការនេះ ប្រធានបទជនក្បត់ត្រូវបានលើកមកនិយាយ ក្នុងវគ្គរៀនសូត្រលើកទីពីរ ដែលគាត់សន្មតថាលោក ខៀវ សំផន ជាអ្នកបង្រៀនវិញម្តង[50]។ ចំពោះមុខភាពផ្ទុយគ្នាជាច្រើននេះ យើងអាចកត់សម្គាល់បានថា អង្គជំនុំជម្រះបានជ្រើសចេញពីសក្ខីកម្មរបស់ ឯក ហេន នូវចម្លើយណាដែលដាក់បន្ទុកលើលោក ខៀវ សំផន ខ្លាំងជាងគេ[51]។ ក៏ប៉ុន្តែ ចម្លើយដែលបានដកស្រង់ក្នុងសំអាងហេតុនៃសាលក្រម ក៏ផ្ទុយគ្នាទៀតនឹងចម្លើយថ្មីៗនេះរបស់គាត់។

២៨. ជាក់ស្តែង ក្នុងកំណត់ហេតុថ្មី ឯក ហេន បានឆ្លើយជាថ្មីម្តងទៀតថា លោក ខៀវ សំផន បានលើកទឹកចិត្តកម្មករឲ្យខំធ្វើការ ជាមួយនឹងការសាមគ្គីគ្នាដើម្បីកសាងប្រទេសជាតិឲ្យរីកចម្រើន[52]។ គាត់ក៏បាននិយាយអំពីរឿងជនក្បត់ នៅមន្ទីរ ៨៧០ ក្នុងនោះ មាន ប៉ង់ ផងដែរ[53]។ ខណៈដែលគាត់មិន

---

[47] ប្រតិចារឹក ថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** ពីម៉ោង [11:10:25] ដល់ម៉ោង [11:17:53] និងពីម៉ោង [11.38.54] ដល់ម៉ោង [11.42.29]។

[48] ប្រតិចារឹក ថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** ពីម៉ោង [11:17:53] ដល់ម៉ោង [11:22:28]។

[49] ប្រតិចារឹក ថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** ពីម៉ោង [11:24:31] ដល់ម៉ោង [11:34:00]។

[50] ប្រតិចារឹក ថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** ពីម៉ោង [14:09:40] ដល់ម៉ោង [14:12:13]។

[51] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៤២៧២។

[52] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ ឯកសារ **E319/71.2.7** ស./ឆ. ៤២។

[53] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ ឯកសារ **E319/71.2.7** ស./ឆ. ៤៣។

ធ្លាប់និយាយអំពីរឿងនេះពីមុនមកទាល់តែសោះ គាត់បានបន្ថែមទៀតថា លោក ខៀវ សំផន បាន លើកឡើងអំពីការក្បត់របស់កម្មាភិបាលភូមិភាគឧត្តរ[54]។ ក៏ប៉ុន្តែ បើតាមសក្ខីកម្ម នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៣ ប្រធានបទនេះត្រូវបានលើកឡើង នៅក្នុងវគ្គរៀនសូត្រលើកទីពីរឯណោះទេ។ ចំពោះលោក នួន ជា វិញ បើតាមកំណត់ហេតុ ឆ្នាំ២០១៧ គាត់បាននិយាយអំពីសភាពការណ៍វឹកវរ ក្នុងប្រទេស ការប្រយុទ្ធគ្នានៅតាមព្រំដែន និងការក្បត់របស់កម្មាភិបាលភូមិភាគឧត្តរ និងភូមិភាគ បូព៌ា ក្នុងវគ្គរៀនសូត្រលើកទីពីរ ដែលគាត់ធ្វើជាអធិបតី នៅឆ្នាំ១៩៧៨[55]។

២៩. ដូច្នេះ ជាក់ស្តែងណាស់ថា ឯក ហេន មានភាពច្របូកច្របល់ចំពោះភាពទាក់ទងគ្នានៃហេតុការណ៍ ដែលគាត់បានអះអាងថាបានចូលរួម។ ប្រសិនបើអង្គជំនុំជម្រះបានយកចិត្តទុកដាក់លើភាពផ្ទុយគ្នា នៃចម្លើយទាំងស្រុងរបស់សាក្សី រួមទាំងនៅក្នុងកំណត់ហេតុចុងក្រោយផងដែរ តាមភាពសមហេតុ ផល អង្គជំនុំជម្រះមិនអាចផ្អែកលើសក្ខីកម្មរបស់សាក្សីនេះ ដើម្បីបង្ហាញថា លោក ខៀវ សំផន បានធ្វើជាអធិបតីក្នុងវគ្គរៀនសូត្រនយោបាយ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ដែលក្នុងពេលនោះ គាត់ បានប្រកាសអំពីការចាប់ខ្លួន ប៉ង់ នោះឡើយ។ ទោះជាយ៉ាងណា នេះជាភ័ស្តុតាងមួយដែលបាននាំ ឲ្យអង្គជំនុំជម្រះឈានដល់ការសន្និដ្ឋានថា លោក ខៀវ សំផន មានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម នៅ តាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២។

### ៣.១.១.២. ការចូលរួមចំណែករបស់លោក ខៀវ សំផន ក្នុងសហឧក្រិដ្ឋកម្មរួម

៣០. នៅក្នុងសំអាងហេតុនៃសាលក្រម អង្គជំនុំជម្រះបានជឿជាក់លើការចូលរួមចំណែករបស់លោក ខៀវ សំផន ក្នុងគោលបំណងរួម ដោយបានសន្និដ្ឋានថា គាត់ "មិនត្រឹមតែមានការគាំទ្រលើគោល បំណងរួមនោះទេ ប៉ុន្តែ គាត់ថែមទាំងបានណែនាំយ៉ាងសកម្មឲ្យអនុវត្តតាមគោលនយោបាយនានា ផងដែរ"[56]។ ដើម្បីឈានដល់ការសន្និដ្ឋាននេះ អង្គជំនុំជម្រះបានផ្អែកជាថ្មីម្តងទៀតតែលើចម្លើយ របស់ ឯក ហេន អំពីវគ្គរៀនសូត្រ ដែលគាត់សន្មតថា លោក ខៀវ សំផន ជាអ្នកបង្រៀន នៅបុរី

---

[54] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ ឯកសារ **E319/71.2.7** ស./ធ. ៤៣។

[55] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ ឯកសារ **E319/71.2.7** ស./ធ. ៥៥ និង ៥៦។

[56] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៤២៧៤។

ក៏ឡា នៅពាក់កណ្ដាលឆ្នាំ១៩៧៨[57]។ ចំពោះមូលហេតុដដែលដូចបានលើកឡើងពីខាងលើ[58] តាមភាពសមហេតុផល អង្គជំនុំជម្រះគួរតែច្រានចោលសក្ខីកម្មនេះ ដោយសារកង្វះភាពអាចជឿជាក់បាននៃចម្លើយមិនទៀងរបស់គាត់ ហើយមិនគួរប្រើប្រាស់សក្ខីកម្មនេះ ដើម្បីធ្វើការសន្និដ្ឋានអំពីការចូលរួមចំណែករបស់លោក ខៀវ សំផន ក្នុងគោលបំណងរួម នោះឡើយ។

៣១. អង្គជំនុំជម្រះក៏មិនគួរផ្អែកលើចម្លើយរបស់ ឯក ហេន ដើម្បីអះអាងថា នៅក្នុងវគ្គរៀនសូត្រដដែលនេះ លោក ខៀវ សំផន បានពន្យល់ថា ខ្មែរ "ត្រូវសាមគ្គីគ្នា ប្រទេសខ្មែរអត់មានយួន"[59]។ គួរកត់សម្គាល់ថា អង្គជំនុំជម្រះបានកំណត់ថា លោក ខៀវ សំផន បាននិយាយបែបនេះ "បន្ទាប់ពីការផ្លាស់ប្ដូរគោលនយោបាយ ប.ក.ក ចំពោះជនជាតិវៀតណាម នៅឆ្នាំ១៩៧៧" ដើម្បីធ្វើការសន្និដ្ឋានអំពីការគាំទ្ររបស់លោក ខៀវ សំផន លើគោលនយោបាយនេះ[60]។ ដើម្បីឈានដល់ការសន្និដ្ឋាននេះ ដែលត្រូវបានជំទាស់តវ៉ានៅក្នុងកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ[61] អង្គជំនុំជម្រះក៏បានផ្អែកលើប្រតិចារឹកនៃបទសម្ភាសន៍របស់វិទ្យុ *"សំឡេងសហរដ្ឋអាមេរិក"* ជាមួយ នៅ សារឹម ដែលបានបញ្ជាក់អះអាងសម្ដីរបស់លោក ខៀវ សំផន[62]។ ក្នុងចេតនាបិទបាំងភាពផ្ទុយគ្នារបស់ ឯក ហេន[63]

---

[57] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៤២៧២ (ការរកឃើញដែលត្រូវបានជំទាស់តវ៉ានៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ៣២ កំហុស ១៨.១៦៣ ១៨.១៦៩ និង ១៨.១៧៣។

[58] សូមមើលខាងលើ ការអធិប្បាយអំពីភាពផ្ទុយគ្នារបស់ ឯក ហេន ពីកថាខណ្ឌ ២១ ដល់កថាខណ្ឌ ២៩ ព្រមទាំងឧបសម្ព័ន្ធ។

[59] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E/465** កថាខណ្ឌ ៤២៧១ (នៅទីនេះ អង្គជំនុំជម្រះបានយោងទៅកថាខណ្ឌ ៣៣៩០ នៃសាលក្រមសំណុំរឿង ០០២/០២ ដែលបានដកស្រង់សម្ដីរបស់ ឯក ហេន ដោយផ្ទាល់ នៅត្រង់កំណត់សម្គាល់ជើងទំព័រលេខ ១១៤៣៧)។

[60] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៤២៧១។

[61] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ៣២ កំហុស ១៨.១៦២ និង ១៨.១៧៣។

[62] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៤២៧១ ដែលយោងទៅកថាខណ្ឌ ៣៣៩០ កំណត់សម្គាល់ជើងទំព័រលេខ ១១៤៣៧ (វិទ្យុសំឡេងសហរដ្ឋអាមេរិក ប្រវត្តិនិយាយរបស់អ្នកស្រី នៅ សារឹម ឯកសារ **E3/6934** ទំព័រ ៧, ១១ និង ១១៣ ERN 01326470-01326477-01326655)។

[63] សូមមើលខាងលើ ភាពផ្ទុយគ្នារបស់ ឯក ហេន ពីកថាខណ្ឌ ២១ ដល់កថាខណ្ឌ ២៩ ព្រមទាំងឧបសម្ព័ន្ធ។

អង្គជំនុំជម្រះចង់បង្កើតដោយសិប្បនិម្មិតនូវភ័ស្តុតាងស៊ីសង្វាក់ជាមួយប្រភពទីពីរនេះ។ ក៏ប៉ុន្តែ អង្គជំនុំជម្រះមិនអាចផ្អែកលើភ័ស្តុតាងណាមួយបានឡើយ ក្នុងចំណោមភ័ស្តុតាងទាំងពីរនេះ។

៣២. ជាក់ស្តែង បទសម្ភាសន៍របស់វិទ្យុ *"សំឡេងសហរដ្ឋអាមេរិក"* ជាមួយ នៅ សារឹម ចោទជាបញ្ហាដោយសារហេតុផលពីរ។ ទីមួយ នេះជាចម្លើយក្រៅក្របខ័ណ្ឌតុលាការ ដែលមានតម្លៃជាភ័ស្តុតាងតិចតួចបំផុត។ ទីពីរ នេះជាចម្លើយដែលមិនអាចយកមកប្រើប្រាស់ជាភ័ស្តុតាងបង្ហាញអំពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទបានឡើយ យោងតាមយុត្តិសាស្ត្រផ្ទាល់របស់អង្គជំនុំជម្រះ (និងតុលាការកំពូល)[64]។ ប៉ុន្តែ អង្គជំនុំជម្រះបានធ្វើ ដោយរំលោភលើវិធានស្តីពីភ័ស្តុតាង ដូចបានរម្លឹកនៅក្នុងសំអាងហេតុនៃសាលក្រម[65]។ ក្នុងករណីបដិសេធជាចំហចំពោះការកោះហៅ នៅ សារឹម តាមការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី[66] ក៏ដូចជាការសួរដេញដោល និងការសួរតទល់ពីភាគីអង្គជំនុំជម្រះមិនអាចយកចម្លើយរបស់គាត់អំពីសម្តីរបស់លោក ខៀវ សំផន មកប្រើបានឡើយ។

---

[64] សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកនៅក្នុងសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ ឯកសារ **E299** កថាខណ្ឌ ១៧ និងកថាខណ្ឌ ២៨, សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ឯកសារ **E96/7** កថាខណ្ឌ ២១ និងកថាខណ្ឌ ២២, ចម្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំឲ្យបំភ្លឺលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលេខ E319/52/4 ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ **E319/52/5**, សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៧០, អង្គជំនុំជម្រះតុលាការកំពូលបានអះអាងបញ្ជាក់លើលក្ខណៈវិនិច្ឆ័យនេះ នៅក្នុងសាលដីកានៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **F36** កថាខណ្ឌ ២៨៤ ដល់កថាខណ្ឌ ២៩៥។

[65] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៦៩ ដល់កថាខណ្ឌ ៧៣។

[66] សេចក្តីសម្រេចស្តីពីសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវបានស្នើសុំស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ **E459** កថាខណ្ឌ ១៨១ ដល់កថាខណ្ឌ ១៨៤ (អង្គជំនុំជម្រះបានសម្រេចមិនស្តាប់សក្ខីកម្ម នៅ សារឹម ពីព្រោះ "សក្ខីកម្មនៅក្នុងតុលាការ របស់ នៅ សារឹម (2-TCCP-268) អាចនឹងមានភាពច្រំដែលយ៉ាងច្រើនទៅនឹងភ័ស្តុតាងនានាដែលអង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរួចហើយ ទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២/០២ ពីក្នុងចំណោមនោះមាន ប៊ិត ឿន (ប៊ិត ណា) (2-TCW-953) នង នេត (2-TCW-913) សុន ឯម (2-TCCP-223) និង សេង លីថេង ហៅ ថេង (2-TCW-897) ដែលបានមកផ្តល់សក្ខីកម្មផងដែរ អំពីការចូលរួមរបស់ជនជាប់ចោទនៅក្នុងវគ្គអប់រំរៀនសូត្រ")។

សំណើរបស់លោក ខៀវ សំផន សុំឲ្យទទួលយកភ័ស្តុតាងបន្ថែម

៣៣. ម្យ៉ាងទៀត ក្រៅពីបញ្ហានៃភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបាននៃប្រភពដកស្រង់ ប្រភពទាំងនេះមិនអាចបង្ហាញតាមការចង់បានរបស់អង្គជំនុំជម្រះទេ។ ទោះជាបីបានរម្លឹកពីគោលការណ៍ជាធរមានស្តីពីភ័ស្តុតាងដែលតុលាការកំពូលបានកំណត់ក៏ដោយ[67] ក៏អង្គជំនុំជម្រះបានប្រញាប់ប្រញាល់ក្នុងការទាញការសន្និដ្ឋានមិនអំណោយផលដល់លោក ខៀវ សំផន ដោយមិនពិចារណាថាតើអាចមានការបកស្រាយគួរឱ្យជឿជាក់បានផ្សេងទៀតដែរឬទេ ដោយផ្អែកលើភ័ស្តុតាងដែលដាក់បង្ហាញក្នុងសវនាការ។ ក្នុងលក្ខខណ្ឌទាំងនេះ អង្គជំនុំជម្រះបានកំណត់ថា សម្តី ដែល ឯក ហេន អះអាងថាលោក ខៀវ សំផន ជាអ្នកនិយាយ កើតឡើង ក្រោយពីការចាប់ខ្លួន ប៉ង់ នៅឆ្នាំ១៩៧៨។ នេះជាមធ្យោបាយតែមួយគត់ ដែលអាចឱ្យអង្គជំនុំជម្រះភ្ជាប់ទំនាក់ទំនងជាមួយគោលនយោបាយ ប.ក.ក ក្នុងការកម្ទេចជនជាតិវៀតណាម ចាប់ពីឆ្នាំ១៩៧៧ មក[68]។ ក៏ប៉ុន្តែ ឃ្លានៃប្រតិចារឹករបស់ ឯក ហេន ដែលអង្គជំនុំជម្រះបានដកស្រង់ និយាយអំពីវគ្គរៀនសូត្រ ដែលលោក ខៀវ សំផន ជាអ្នកបង្រៀន នៅឆ្នាំ១៩៧៦ គឺមិនមែននៅឆ្នាំ១៩៧៨ នោះទេ! កាលបរិច្ឆេទនេះមិនត្រឹមតែខុសគ្នាជាមួយកាលបរិច្ឆេទចាប់ខ្លួន ប៉ង់ ប៉ុណ្ណោះទេ ថែមទាំងខុសគ្នាជាមួយគោលនយោបាយកម្ទេចជនជាតិវៀតណាម ដែលអង្គជំនុំជម្រះបានកំណត់យក ទៀតផង។ ការបកស្រាយផ្សេងទៀតមិនត្រឹមតែអាចមានប៉ុណ្ណោះទេ ថែមទាំងគួរឱ្យជឿជាក់បានទៀតផង។

៣៤. ដូច្នេះ សម្តីរបស់ ឯក ហេន ត្រូវគ្នាជាងជាមួយការបញ្ជូនជនជាតិវៀតណាមត្រឡប់ទៅស្រុកវិញ នៅមុន ឬដើមរបបនោះ។ ម្យ៉ាងវិញទៀត ខ្លឹមសារប្រតិចារឹកនៃបទសម្ភាសន៍របស់វិទ្យុ *"សំឡេងសហរដ្ឋអាមេរិក"* ជាមួយ នៅ សារឹម[69] ស៊ីសង្វាក់គ្នានឹងន័យនេះជាង ពីព្រោះ នៅ សារឹម បានបញ្ជាក់ថា ក្នុងវគ្គរៀនសូត្រនយោបាយ នៅវិទ្យាស្ថានខ្មែរ-សូវៀត លោក ខៀវ សំផន បានពន្យល់

---

[67] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៦៥ ដែលយោងទៅសាលដីកានៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **F36** កថាខណ្ឌ ៩៧០។

[68] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៤២៧១, សូមមើលផងដែរ កថាខណ្ឌ ៣៣៩០ កំណត់សម្គាល់ជើងទំព័រលេខ ១១៤៣៧ "អង្គជំនុំជម្រះកត់សម្គាល់ថា ឯក ហេន បានផ្តល់សក្ខីកម្មថា មានតែខ្មែរ អត់មានយួនទេ នៅក្នុងប្រទេសកម្ពុជានៅពេលនោះ។ អង្គជំនុំជម្រះក៏បានរម្លឹកឡើងវិញផងដែរថា វគ្គបណ្តុះបណ្តាលនេះត្រូវបានធ្វើឡើង បន្ទាប់ពី ប៉ង់ ត្រូវបានចោទប្រកាន់ (គាត់ត្រូវបានចាប់ខ្លួននៅក្នុង ឬប្រហែលខែមេសា ឆ្នាំ១៩៧៨)"។

[69] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៤២៧១ ដែលយោងទៅកថាខណ្ឌ ៣៣៩០ កំណត់សម្គាល់ជើងទំព័រលេខ ១១៤៣៧ "វិទ្យុសំឡេងសហរដ្ឋអាមេរិក ប្រវត្តិនិយាយរបស់អ្នកស្រី នៅ សារឹម ឯកសារលេខ **E3/6934** ទំព័រ ៧, ១១ និង ១១៣ ERN 01326470-01326477-01326655"។

ថា ជនជាតិវៀតណាមដែលមិនចេះធ្វើស្រែ ត្រូវបញ្ជូនទៅវៀតណាមវិញ[70]។ ច្បាស់ណាស់ថា ក្នុងបរិបទនេះ សម្ដីទាំងនេះសំដៅដល់ការបញ្ជូនជនជាតិវៀតណាមដែលមានវត្តមានក្នុងទឹកដីកម្ពុជាឱ្យត្រឡប់ទៅស្រុកវិញ នៅមុនឆ្នាំ១៩៧៨។ ក្នុងគ្រប់ករណីទាំងអស់ ទោះត្រូវ ឬខុសក៏ដោយ ការនិយាយសំដៅនេះមិនស៊ីសង្វាក់គ្នាទាល់តែសោះនឹងអ្វីដែលអង្គជំនុំជម្រះចង់បង្ហាញ ជាមួយនឹងចម្លើយរបស់ ឯក ហេន អំពីការគាំទ្ររបស់លោក ខៀវ សំផន ដល់គោលនយោបាយកម្ទេចជនជាតិវៀតណាម។ អង្គជំនុំជម្រះមិនអាចធ្វើអ្វីបានច្រើនទេ ពីព្រោះក្នុងកំណត់ហេតុថ្មី ដែលស្នើសុំដាក់បញ្ចូលជាភ័ស្តុតាង ឯក ហេន បានអះអាងថា លោក ខៀវ សំផន លើកទឹកចិត្តឱ្យខ្មែរដូចគ្នា "ចេះស្រឡាញ់គ្នា សាមគ្គីគ្នា កុំក្បត់គ្នា" និងមិនបានលើកឡើងអំពីការប្រើប្រាស់ពាក្យ "យួន" ទាល់តែសោះ[71]។

៣៥. ហេតុនេះ អង្គជំនុំជម្រះមិនអាចផ្អែកជាស្ថាពរលើចម្លើយរបស់ ឯក ហេន ដើម្បីបង្ហាញអំពីការរកឃើញផ្នែកអង្គហេតុចំពោះលោក ខៀវ សំផន ឬលើប្រតិចារឹកនៃបទសម្ភាសន៍របស់វិទ្យុ *"សំឡេងសហរដ្ឋអាមេរិក"* ជាមួយ នៅ សារឹម បានឡើយ។ កង្វះមូលដ្ឋាន សម្រាប់ការរកឃើញបែបនេះ គួរតែនាំឱ្យអង្គជំនុំជម្រះប្រកាសសាលក្រមផ្សេងពីនេះទាំងស្រុង ឬដោយផ្នែក បើយោងតាមការទាញការសន្និដ្ឋានរបស់ខ្លួនអំពីការចូលរួមចំណែករបស់លោក ខៀវ សំផន ក្នុងសហឧក្រិដ្ឋកម្មរួម។

### ៣.១.១.៣. ការដឹងរបស់លោក ខៀវ សំផន ក្រោយហេតុការណ៍កើតឡើង

៣៦. អង្គជំនុំជម្រះក៏បានផ្អែកលើសក្ខីកម្មរបស់ ឯក ហេន ដើម្បីអះអាងថា លោក ខៀវ សំផន បាន "ចូលរួម និងបង្រៀននៅក្នុងវគ្គអប់រំ និងមិទ្ទីងមហាជន ដែលនៅពេលនោះ អំពើដែលត្រូវបានចាត់ទុកថាមានលក្ខណៈឧក្រិដ្ឋប្រឆាំងទៅលើខ្មាំង ប.ក.ក ត្រូវបានយកទៅពិភាក្សា លើកទឹកចិត្ត និងញុះញង់ រួមទាំងប្រឆាំងនឹងជនជាតិវៀតណាម អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី និងពួកផ្ដាច់ខ្លួននៅក្នុងជួរបដិវត្តន៍ដទៃទៀត"[72]។

---

[70] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៤២៧១ ដែលយោងទៅកថាខណ្ឌ ៣៣៩០ កំណត់សម្គាល់ជើងទំព័រលេខ ១១៤៣៧។

[71] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក ហេន ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ **E319/71.2.7** ស./ឆ. ៥០ និង ៥១។

[72] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៤២៥៣។

៣៧. ការរកឃើញផ្នែកអង្គហេតុនេះ ដែលត្រូវបានជំទាស់តវ៉ាក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ[73] មានលក្ខណៈទូលំទូលាយ និងទូទៅពេក ធ្វើឱ្យពិបាកកំណត់ប្រភព។ ជាក់ស្តែង អង្គជំនុំជម្រះបានយោងទៅរកឯកសារច្រើនសន្ធឹកសន្ធាប់ ដែលមិនអាចឱ្យមេធាវីការពារក្តីកំណត់បានថា តើអង្គជំនុំជម្រះបានផ្អែកលើសេចក្តីយោងជាក់លាក់ណាខ្លះ។ ជាក់ស្តែង អង្គជំនុំជម្រះបានយោងទៅកថាខណ្ឌ ៤២៧១ ដល់កថាខណ្ឌ ៤២៧៣ ដែលយោងបន្តទៅកថាខណ្ឌផ្សេងទៀត នៅក្នុងផ្នែកផ្សេងទៀតនៃសំអាងហេតុនៃសាលក្រម ដែលយោងបន្តទៀតទៅកថាខណ្ឌផ្សេងទៀត! ការយោងជាច្រើននេះធ្វើឱ្យជាចុងក្រោយ ប្រភពមិនបានលើកឡើងអំពីលោក ខៀវ សំផន ទាល់តែសោះ[74]។ មានករណីមួយផងដែរ ដែលកំណត់សម្គាល់ជើងទំព័រយោងទៅកថាខណ្ឌដដែល ដែលភ្ជាប់នឹងកំណត់សម្គាល់ជើងទំព័រនោះ ធ្វើឱ្យមិនអាចកំណត់ប្រភពដែលប្រើប្រាស់បាន[75]។ ក្រៅពីនេះ ជារឿយៗ អង្គជំនុំជម្រះបានយោងទៅផ្នែកនេះផ្នែកនោះទាំងស្រុងតែម្តង ដោយគ្មានបញ្ជាក់កថាខណ្ឌណាជាក់លាក់ ធ្វើឱ្យលំបាកក្នុងការដឹងថា តើអង្គជំនុំជម្រះបានផ្អែកលើប្រភពណាខ្លះ ដើម្បីទាញការសន្និដ្ឋាន[76]។

---

[73] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ៣២ កំហុស ១៨.១១៥។

[74] ជាឧទាហរណ៍ កថាខណ្ឌ ៤២៥៣ ដែលលើកឡើងនោះ បានយោងទៅកថាខណ្ឌ ៤២៧១ ដល់កថាខណ្ឌ ៤២៧៣ (កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៤០) ដែលយោងទៅកថាខណ្ឌ ៤០៥៤ ដែលយោងទៅកថាខណ្ឌ ៣៧៣៦ ដែលយោងទៅកថាខណ្ឌ និងផ្នែកជាច្រើនទៀត៖ កថាខណ្ឌ ៣៩៤២ និងកថាខណ្ឌ ៣៩៤៣ នៅក្នុងផ្នែក ១០.១.៩ យោងទៅកថាខណ្ឌ ៤០៣៨ និងផ្នែក ១០.១.៦.៣, ១៣.៣.៥ និង ១៣.២។ ក៏ប៉ុន្តែ កថាខណ្ឌ ៤០៣៨ ជាឧទាហរណ៍ មិនបាននិយាយសោះពីលោក ខៀវ សំផន តែនិយាយពី សុន សេន។

[75] ជាឧទាហរណ៍ កថាខណ្ឌ ៤២៥៣ ដែលបានលើកឡើងនោះ បានយោងទៅកថាខណ្ឌ ៤២៧២ ដែលមានកំណត់សម្គាល់ជើងទំព័រលេខ ១៣៩៤១ ក៏យោងទៅកថាខណ្ឌ ៤២៧២ ដដែលនេះដែរ។

[76] ដូចឧទាហរណ៍ខាងលើដែរ៖ កថាខណ្ឌ ៤២៥៣ ដែលបានលើកឡើងនោះ យោងទៅកថាខណ្ឌ ៤២៧១ ដល់កថាខណ្ឌ ៤២៧៣ (កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៤០) យោងទៅកថាខណ្ឌ ៤០៥៤ ដែលយោងទៅកថាខណ្ឌ ៣៧៣៦ ដែលយោងទៅកថាខណ្ឌ និងផ្នែកជាច្រើនទៀត៖ កថាខណ្ឌ ៣៩៤២ និងកថាខណ្ឌ ៣៩៤៣ នៅក្នុងផ្នែក ១០.១.៩ យោងទៅកថាខណ្ឌ ៤០៣៨ និងផ្នែក ១០.១.៦.៣, ១៣.៣.៥ និង ១៣.២។

៣៨. ប៉ុន្តែ យើងឃើញច្បាស់ថា ឯក ហេន គឺជាប្រភពដ៏សំខាន់ សម្រាប់គាំទ្រដល់ការអះអាងនេះ[77]។ ដោយសារមូលហេតុដូចបានរៀបរាប់លម្អិតខាងលើ ពាក់ព័ន្ធនឹងភាពផ្ទុយគ្នាដែលបានរកឃើញនៅក្នុងចម្លើយរបស់គាត់[78] អង្គជំនុំជម្រះមិនគួរណាផ្អែកលើសាក្សីនេះ ដើម្បីឈានដល់ការរកឃើញផ្នែកអង្គហេតុ ដែលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងវិចារណកិច្ចរបស់អង្គជំនុំជម្រះ។ ជាក់ស្តែង អង្គជំនុំជម្រះបានប្រើប្រាស់សាក្សីនេះ ដើម្បីបង្ហាញអំពីការដឹងរបស់លោក ខៀវ សំផន អំពីឧក្រិដ្ឋកម្ម ក្រោយពេលប្រព្រឹត្ត[79]។

## ៣.១.២. ផលប៉ះពាល់លើគោលបំណងរួម

៣៩. ចម្លើយរបស់ ឯក ហេន ក៏ត្រូវបានយកមកប្រើប្រាស់ផងដែរ ដើម្បីផ្សារភ្ជាប់លោក ខៀវ សំផន ទៅនឹងការអនុវត្តគោលបំណងរួម (៣.១.២.១) និងការរៀបចំគោលបំណងរួម (៣.១.២.២)។

### ៣.១.២.១. ការអនុវត្តគោលបំណងរួម តាមរយៈគោលនយោបាយ

៤០. អង្គជំនុំជម្រះបានសន្និដ្ឋានអំពីអត្ថិភាពនៃគោលនយោបាយជាច្រើន បណ្តាលឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដើម្បីអនុវត្តគោលបំណងរួម ដែលលោក ខៀវ សំផន បានចូលរួមចំណែក។ អង្គជំនុំជម្រះបានយកចម្លើយរបស់ ឯក ហេន មកប្រើទៀត ក្នុងការអធិប្បាយរបស់ខ្លួន ដើម្បីគាំទ្រដល់ការបង្ហាញអំពីគោលនយោបាយក្នុងការបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានការងារ និងគោលនយោបាយចាត់វិធានការប្រឆាំងនឹងជនជាតិវៀតណាម និងជនជាតិចាម។

---

[77] សាលក្រមសំណុំរឿង 00២/0២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៤២៥៣ (យោងទៅកថាខណ្ឌ ៤២៧១-៤២៧៣ ដែលបង្ហាញអំពីចម្លើយរបស់ ឯក ហេន អំពីវគ្គរៀនសូត្រនយោបាយ ដែលលោក ខៀវ សំផន បានបង្រៀននៅបុរីកីឡា នៅពាក់កណ្តាលឆ្នាំ១៩៧៨៖ សូមមើលកំណត់សម្គាល់ជើងទំព័រលេខ ១៣៩៣៨ (យោងទៅកថាខណ្ឌ ៣៣៩០ កំណត់សម្គាល់ជើងទំព័រលេខ ១១៤៣៧), កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៣៩ (យោងទៅកថាខណ្ឌ ៣៥១៧ រួចយោងទៅកថាខណ្ឌ ៣៣៩០ កំណត់សម្គាល់ជើងទំព័រលេខ ១១៤៣៦) កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៤៤ (យោងទៅកថាខណ្ឌ ៦២០) កំណត់សម្គាល់ជើងទំព័រលេខ ១៣៩៤៧ (យោងទៅកថាខណ្ឌ ៣៩១៦ កំណត់សម្គាល់ជើងទំព័រលេខ ១៣០៧២))។

[78] សូមមើលខាងលើ ការអធិប្បាយអំពីភាពផ្ទុយគ្នារបស់ ឯក ហេន ពីកថាខណ្ឌ ២១ ដល់កថាខណ្ឌ ២៩ ព្រមទាំងឧបសម្ព័ន្ធ។

[79] សាលក្រមសំណុំរឿង 00២/0២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៤២៥៤។

## ការប្រើប្រាស់ចម្លើយរបស់ ឯក ហេន ដើម្បីគាំទ្រដល់គោលនយោបាយបង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានការងារ

៤១. បើតាមអង្គជំនុំជម្រះ គោលនយោបាយ "បង្កើត និងប្រតិបត្តិការសហករណ៍ និងការដ្ឋានការងារ"[80] មានវត្ថុបំណង ជាអាទិ៍ សម្រេចបាននូវ "គោលដៅសេដ្ឋកិច្ច និងមនោគមន៍វិជ្ជា"[81]។ អង្គជំនុំជម្រះបានផ្អែកលើសក្ខីកម្មរបស់ ឯក ហេន ដើម្បីអះអាងថា "នួន ជា និង ខៀវ សំផន បានបង្រៀនដល់កម្មាភិបាលអំពីការបំពេញគោលដៅសេដ្ឋកិច្ច និងផលិតកម្ម"[82]។ ការរកឃើញផ្នែកអង្គហេតុនេះត្រូវបានជំទាស់តវ៉ាក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ[83]។ មានតែចម្លើយរបស់ ឯក ហេន ប៉ុណ្ណោះដែលនិយាយសំដៅដល់លោក ខៀវ សំផន ឯប្រភពដកស្រង់ផ្សេងទៀតនិយាយតែពីលោក នួន ជា មួយគត់។ ក៏ប៉ុន្តែ កង្វះភាពអាចជឿជាក់បានរបស់ ឯក ហេន ដែលកាន់តែច្បាស់ក្រឡែតថែមទៀត នៅពេលអានកំណត់ហេតុ ឆ្នាំ២០១៧ របស់គាត់ គួរណាតែរារាំងអង្គជំនុំជម្រះមិនឲ្យទាញសេចក្តីសន្និដ្ឋានបែបនេះលើលោក ខៀវ សំផន។

## ការប្រើប្រាស់ចម្លើយរបស់ ឯក ហេន ដើម្បីគាំទ្រដល់គោលនយោបាយចាត់វិធានការប្រឆាំងនឹងជនជាតិវៀតណាម

៤២. អង្គជំនុំជម្រះក៏បានសន្និដ្ឋានអំពីអត្ថិភាពនៃ "គោលនយោបាយដែលបានរៀបចំឡើងដោយមជ្ឈិមបក្ស សំដៅចាត់វិធានការប្រឆាំងនឹងជនជាតិវៀតណាម"[84]។ ដើម្បីសម្រេចគោលដៅនេះ អង្គជំនុំ

---

[80] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៩១៨។

[81] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៩១៦។

[82] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៩១៦ កំណត់សម្គាល់ជើងទំព័រលេខ ១៣០៧២។

[83] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ៣១ កំហុស ១៦.១៥៨ និង ១៦.១៥៩។

[84] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៤១៧។

ជម្រះបានផ្តែកជាពិសេសលើសក្ខីកម្មរបស់ ឯក ហេន ដើម្បីទាញសេចក្តីសន្និដ្ឋានអំពីការរកឃើញផ្នែកអង្គហេតុជាច្រើន ដែលមេធាវីការពារក្តីជំទាស់។ បើតាមអង្គជំនុំជម្រះ៖

"អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មពីសាក្សីមួយចំនួន ដែលបានបញ្ជាក់ថា ចាប់ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨ ប៉ុល ពត នួន ជា ខៀវ សំផន និងមេដឹកនាំជាន់ខ្ពស់របស់ ប.ក.ក ដទៃទៀត បានបង្រៀន ឬចូលរួមវគ្គបណ្តុះបណ្តាលផ្នែកនយោបាយ ដែលពេលនោះ វៀតណាម ឬភ្នាក់ងារវៀតណាមត្រូវបានចាត់ទុកថាជាខ្មាំង"[85]។

៤៣. ឯក ហេន គឺជាសាក្សីតែម្នាក់គត់ ដែលអាចឲ្យអង្គជំនុំជម្រះអះអាងថា លោក ខៀវ សំផន បាននិយាយអំពីជនជាតិវៀតណាម ក្នុងពេលប្រជុំរៀនសូត្រ។ ជាក់ស្តែង សាក្សីពីរនាក់ផ្សេងទៀត គឺ ពាន ឃាន និង មុំ វុន ដែលបាននិយាយអំពីវត្តមានរបស់លោក ខៀវ សំផន នៅក្នុងកិច្ចប្រជុំរៀនសូត្រ[86] បានអះអាងថា គាត់បានចូលរួម ដោយមិននិយាយអ្វីទេ។ សាក្សីផ្សេងទៀតមិនបានលើកឈ្មោះលោក ខៀវ សំផន ទេ។ ដូច្នេះ ថ្វីត្បិតតែការយោងនៅកថាខណ្ឌ ៦០៧ ដាក់បញ្ចូលប្រភពជាច្រើន មានតែចម្លើយរបស់ ឯក ហេន ប៉ុណ្ណោះ ដែលនិយាយសំដៅដល់លោក ខៀវ សំផន ពាក់ព័ន្ធនឹងរឿងជនជាតិវៀតណាម[87]។ ចំពោះការយោងនៅកថាខណ្ឌខ្លះនៃផ្នែកស្តីពីមន្ទីរសន្តិសុខ ស-២១ គ្មានការនិយាយសំដៅដល់លោក ខៀវ សំផន ទេ។ តាមភាពសមហេតុផល អង្គជំនុំជម្រះ

[85] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៣៩០ (ការរកឃើញដែលត្រូវបានជំទាស់តវ៉ានៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ២៨ កំហុស ១៣.១២៦ និង ១៣.១២៧)។

[86] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៣៩០ កំណត់សម្គាល់ជើងទំព័រលេខ ១១៤៣៦ "ប្រតិចារឹក ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១២ ឯកសារ (ពាន ឃាន) ឯកសារ **E1/72.1** ទំព័រ ២១ (ប៉ង់ បានបង្រៀនពីខ្មាំងថាជាអ្នក "ដែលជា [...] ភ្នាក់ងារយួន"), ប្រតិចារឹក ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២ (ពាន ឃាន) ឯកសារ **E1/73.1** ទំព័រ ១៧-១៨, ២០ (កិច្ចប្រជុំនៅបុរីកីឡាដែល ប៉ង់ បានណែនាំ ត្រូវបានចូលរួមដោយ នួន ជា និង ខៀវ សំផន), ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ (មុំ វុន) ឯកសារ **E1/475.1** ទំព័រ ៥០, ៥៦-៥៧ (នៅក្នុងកិច្ចប្រជុំមួយដែលចូលរួមដោយ នួន ជា, ខៀវ សំផន និង អៀង សារី នៅភ្នំគូលែន ក្នុងឆ្នាំ១៩៧៦ នួន ជា បានមានប្រសាសន៍ថា "ខ្មាំងបដិវត្តន៍ គឺយួន)។

[87] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៦០៧ កំណត់សម្គាល់ជើងទំព័រលេខ ១៩០៤។

មិនអាចទាញការសន្និដ្ឋានពីការចាត់វិធានការរបស់លោក ខៀវ សំផន ប្រឆាំងជនជាតិវៀតណាម ចេញពីសក្ខីកម្មរបស់ ឯក ហេន បានទេ ពីព្រោះសក្ខីកម្មរបស់គាត់ខ្វះភាពអាចជឿជាក់បាន។

៤៤. ដោយសារហេតុផលដូចគ្នានេះ អង្គជំនុំជម្រះមិនគួរណារកឃើញដូចខាងក្រោមទេ៖

"សាក្សី ឯក ហេន ដែលជាអ្នកធ្វើការនៅក្នុងអង្គភាពរោងចក្រកាត់ដេរមួយស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរ ៨៧០ បានផ្តល់សក្ខីកម្មថា គាត់ និងអ្នកចូលរួមផ្សេងទៀតប្រហែលពី ៤០០ ទៅ ៥០០ នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលមួយដែលធ្វើឡើងដោយ ខៀវ សំផន ដែលពេលនោះ គាត់បានពន្យល់ថា យើងត្រូវសាមគ្គីគ្នា ប្រទេសខ្មែរអត់មានយួន ខ្មែរ និងខ្មែរចេះស្រឡាញ់គ្នា"[88]។

៤៥. ជាចុងក្រោយ អង្គជំនុំជម្រះមិនគួរណាអះអាងថា៖

"ពេញមួយឆ្នាំ១៩៧៨ និងដើមឆ្នាំ១៩៧៩ ប៉ុល ពត និង ខៀវ សំផន បានបន្តសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការការពារ និងថែរក្សាសមិទ្ធផលបដិវត្តន៍ និងពូជសាសន៍កម្ពុជា ពីវៀតណាមវាតទីនិយម និងទេសានុពន្ធន៍និយម"[89]។

៤៦. ខណៈដែលអង្គជំនុំជម្រះបានផ្អែកជាចម្បងលើសុន្ទរកថារបស់លោក ខៀវ សំផន ដែលភាគច្រើនយកចេញពី SWB និង FBIS ដែលមានតម្លៃជាភស្តុតាងទាប[90] អង្គជំនុំជម្រះក៏លើកយកចម្លើយ

---

[88] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៣៩០ (ការរកឃើញដែលត្រូវបានជំទាស់តវ៉ានៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ២៨ កំហុស ១៣.១២៨)។ សក្ខីកម្មរបស់ ឯក ហេន នៅក្នុងផ្នែកនេះ ក៏ត្រូវបានអង្គជំនុំជម្រះប្រើប្រាស់នៅក្នុងផ្នែកស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន ដែលយើងខ្ញុំបានលើកឡើង និងជំទាស់ ដោយបង្ហាញពីតួនាទីដ៏សំខាន់នៃភស្តុតាងនេះ ក្នុងការផ្តន្ទាទោស លោក ខៀវ សំផន៖ សូមមើលផងដែរ ការអធិប្បាយខាងលើ កថាខណ្ឌ ៣១ ដល់កថាខណ្ឌ ៣៥។

[89] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៤០៦ (ការរកឃើញដែលត្រូវបានជំទាស់តវ៉ានៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ២៨ កំហុស ១៣.១៤៤)។

[90] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៤០៦ កំណត់សម្គាល់ជើងទំព័រ

សំណើរបស់លោក ខៀវ សំផន សុំឱ្យទទួលយកភស្តុតាងបន្ថែម

របស់ ឯក ហេន ផងដែរ ក្នុងសម្រង់ដដែលដែលត្រូវបានកែឆ្នៃជ្រុលហួសហេតុ[91]។ ដូចយើងបាន ឃើញពីខាងលើ អង្គជំនុំជម្រះមិនគួរណាផ្អែកលើសក្ខីកម្មរបស់ ឯក ហេន ដែលពោរពេញទៅ ដោយភាពផ្ទុយគ្នា ជាពិសេស ពាក់ព័ន្ធនឹងវគ្គរៀនសូត្រ ដែលបង្រៀនដោយលោក ខៀវ សំផន នៅ ឆ្នាំ១៩៧៦។

## ការប្រើប្រាស់ចម្លើយរបស់ ឯក ហេន ដើម្បីគាំទ្រដល់គោលនយោបាយចាត់វិធានការប្រឆាំងនឹងជនជាតិចាម

៤៧. ដើម្បីសន្និដ្ឋានអំពីអត្ថិភាពនៃគោលនយោបាយសំដៅចាត់វិធានការ "ប្រឆាំងនឹងជនជាតិចាម ដែល ជាក្រុមជាតិពន្ធមួយ និងសាសនាមួយដាច់ដោយឡែកពីគេ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ"[92] អង្គជំនុំជម្រះបានប្រើទឡ្ហីករណ៍ដដែលដូចគ្នានឹងជនជាតិវៀតណាម ដោយយល់ឃើញថា ប.ក.ក គាំទ្រដល់ "ឧត្តមានុភាពដាច់ខាតនៃជាតិសាសន៍ខ្មែរ នៅក្នុងប្រទេសកម្ពុជា" ហើយ "ខៀវ សំផន ក៏បានសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការការពារ និងការថែរក្សាសមិទ្ធផលបដិវត្តន៍ និងជាតិ សាសន៍ កម្ពុជាឲ្យបានជារៀងរហូត នៅក្នុងសុន្ទរកថារបស់គាត់ផងដែរ"[93]។ ម្យ៉ាងទៀត គ្មានអ្វីគួរ ឲ្យភ្ញាក់ផ្អើលទេក្នុងការមើលឃើញថា ដើម្បីគាំទ្រដល់អំណះអំណាងនេះ ដែលត្រូវបានជំទាស់តវ៉ា ផងដែរនៅក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ[94] អង្គជំនុំជម្រះបានបង្ហាញប្រភពដដែលដូចគ្នា

---

លេខ ១១៤៨៤។

[91] សូមមើលខាងលើ កថាខណ្ឌ ៤៣។

[92] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣២២៨។ សូមមើលផងដែរ កថាខណ្ឌ ៣៩៩៨ (សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះស្តីពីលក្ខណៈឧក្រិដ្ឋនៃគោលនយោបាយ ដែលមានទំនាក់ទំនងដោយផ្ទាល់ ទៅនឹងគោលបំណងរួម)។

[93] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣២១៦។

[94] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ២៨ កំហុស ១៣.២៦ និង ១៣.២៧។

បេះបិទនឹងការរកឃើញពាក់ព័ន្ធនឹងជនជាតិវៀតណាម[95]។ ក្នុងគំនិតដូចគ្នានេះ អង្គជំនុំជម្រះបាន ដកស្រង់ជាថ្មីម្តងទៀតនូវចម្លើយដដែលរបស់ ឯក ហេន[96]។

៤៨. ដូចបានបង្ហាញពីខាងលើ[97] អង្គជំនុំជម្រះមិនអាចផ្អែកលើសាក្សីនេះ ដើម្បីទាញសេចក្តីសន្និដ្ឋានដ៏សំខាន់ សម្រាប់ការផ្តន្ទាទោសលោក ខៀវ សំផន បានទេ។ ចម្លើយដដែលរបស់ ឯក ហេន ត្រូវបានអង្គជំនុំជម្រះដកស្រង់ជាប្រព័ន្ធ ដើម្បីបង្ហាញពីរឿងផ្សេងៗគ្នា។ នេះជាឧទាហរណ៍ជាក់ស្តែងនៃការកែច្នៃ និងការលើកឡើងច្រំដែលជាប្រព័ន្ធរបស់អង្គជំនុំជម្រះ នូវភ័ស្តុតាងអាចជំទាស់បាន ដើម្បីព្យាយាមប៉ះប៉ូវកង្វះភ័ស្តុតាងផ្ទាល់ពិតប្រាកដ និងផ្តន្ទាទោសលោក ខៀវ សំផន។

### ៣.១.២.២. ការរៀបចំគោលបំណងរួម

៤៩. អង្គជំនុំជម្រះបានសន្និដ្ឋានថា មានគោលបំណងរួមក្នុងការ "អនុវត្តបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័ស នៅក្នុងប្រទេសកម្ពុជា តាមរយៈមហាលោតផ្លោះ មហាអស្ចារ្យ ដែលត្រូវបានបង្កើតឡើង ដើម្បីកសាង ការពារប្រទេសឲ្យរួចផុតពីសត្រូវ និងផ្លាស់ប្តូរប្រជាជនទាំងស្រុងឲ្យក្លាយទៅជាសង្គមខ្មែររួបរួមគ្នាមួយ ដែលមានតែវណ្ណៈកម្មករ-កសិករ"[98]។ ដើម្បីឈានដល់ការធ្វើសេចក្តីសន្និដ្ឋាននេះ ដែលជាធាតុផ្សំដ៏សំខាន់មួយទៀតសម្រាប់ការផ្តន្ទាទោសលោក ខៀវ សំផន អង្គជំនុំជម្រះបានអះអាងជាពិសេសថា៖

---

[95] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣២១៦ កំណត់សម្គាល់ជើងទំព័រលេខ ១០៨២៥ ដែលយោងទៅផ្នែក ១៣.៣៖ ការប្រព្រឹត្តិចំពោះជនជាតិវៀតណាម យោងទៅសុន្ទរកថារបស់ ខៀវ សំផន ដូចក្នុងកំណត់សម្គាល់ជើងទំព័រលេខ ១១៤៨៤។

[96] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣២១៦ កំណត់សម្គាល់ជើងទំព័រលេខ ១០៨២៥៖ "គាត់ [ខៀវ សំផន] ថា យើងត្រូវសាមគ្គីគ្នា ប្រទេសខ្មែរអត់មានយួន គឺមានតែខ្មែរ ខ្មែរនិងខ្មែរចេះស្រឡាញ់គ្នា"។

[97] សូមមើលខាងលើ ការអធិប្បាយអំពីភាពផ្ទុយគ្នារបស់ ឯក ហេន ពីកថាខណ្ឌ ២១ ដល់កថាខណ្ឌ ២៩ ព្រមទាំងឧបសម្ព័ន្ធ។

[98] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៧៤៣។

"ប៉ុល ពត នួន ជា ខៀវ សំផន និងមេដឹកនាំជាន់ខ្ពស់ដទៃទៀត បានឧទ្ទេសនាមបន្ថែមទៅកម្មាភិបាល នៅក្នុងវគ្គរៀនសូត្រទ្រង់ទ្រាយធំ ស្ដីពីភាពចាំបាច់ក្នុងការខិតខំហូបតិច និងសម្រាកតិច និងបំពេញគោលដៅរបស់បក្ស ទោះក្នុងតម្លៃណាក៏ដោយ"[99]។

៥០. ដើម្បីគាំទ្រដល់ការរកឃើញនេះ ឯក ហេន នៅតែជាប្រភពមួយរបស់អង្គជំនុំជម្រះ ដែលបានដកស្រង់ដូចខាងក្រោម៖

"ការបង្រៀនចាប់ផ្ដើមជាមួយ ខៀវ សំផន ពន្យល់ណែនាំពួកកម្មករទាំងអស់ឲ្យខំប្រឹងធ្វើការជួយប្រទេសជាតិ។ [...] មិនមាននាំឲ្យយើងមានទំនាស់ទាស់ទែងគ្នាអី គាត់ឲ្យចេះសាមគ្គីគ្នាក្នុងក្រុមក្នុងកង ពលកម្មដើម្បីស្ដារសេដ្ឋកិច្ចប្រទេសជាតិ។ យើងកំពុងតែរួចផុតពីសង្គ្រាម"[100]។

៥១. តាមរយៈសម្រង់នេះផ្ទាល់តែម្ដង អង្គជំនុំជម្រះបានផ្ទុះបញ្ចាំងអំពីភាពផ្ទុយគ្នារបស់សាក្សី ដោយមិនបង្ហាញឡើង។ ជាក់ស្ដែង ឯក ហេន បានរៀបរាប់ពីសម្ដី ដែលលោក ខៀវ សំផន បាននិយាយនៅបុរីកីឡា អំពី "ការស្ដារសេដ្ឋកិច្ចប្រទេសជាតិ [ពីព្រោះ] <u>យើងកំពុងតែរួចផុតពីសង្គ្រាម</u>"។ នៅពេលមេធាវីការពារក្ដីសួរដេញដោល គាត់បានបញ្ជាក់ថានេះជាសង្គ្រាមជាមួយរបប លន់ នល់[101]។ ដូច្នេះ យោងតាមសម្រង់នេះ សម្ដីរបស់លោក ខៀវ សំផន គឺនៅឆ្នាំ១៩៧៦ មិនមែន "ពាក់កណ្ដាលឆ្នាំ១៩៧៨" ដូចអង្គជំនុំជម្រះបានអះអាងនៅក្នុងសំអាងហេតុនៃសាលក្រមទេ[102]។ ជាថ្មីម្ដងទៀត ចៅក្រមមានវិចារណញ្ញាណគួរណាតែកត់សម្គាល់ឃើញអំពីភាពផ្ទុយគ្នាដ៏សំខាន់នេះ រួចទាញផលវិបាក ដោយច្រានចោលសក្ខីកម្មរបស់ ឯក ហេន។

---

[99] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៧៣៩ (ការរកឃើញដែលត្រូវបានជំទាស់តវ៉ានៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ៣១ កំហុស ១៦.៥ និង ១៦.១២)។

[100] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៧៣៩ កំណត់សម្គាល់ជើងទំព័រលេខ ១២៤៧៣។

[101] ប្រតិចារឹក ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ **E1/217.1** ពីម៉ោង [14:05:55] ដល់ម៉ោង [14:09:40]។

[102] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៣៩០ កថាខណ្ឌ ៣៤០៦ កថាខណ្ឌ ៤២៧១ និងកថាខណ្ឌ ៤២៧២។

## ៣.១.៣. ផលប៉ះពាល់លើតួនាទី និងមុខងាររបស់លោក ខៀវ សំផន

៥២. ជាចុងក្រោយ អង្គជំនុំជម្រះបានយកសក្ខីកម្មរបស់ ឯក ហេន អំពីវគ្គរៀនសូត្រ ក្រោមអធិបតីភាព លោក ខៀវ សំផន នៅបុរីកីឡា មកបង្ហាញអំពីសារៈសំខាន់នៃតួនាទីរបស់គាត់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយទាញការសន្និដ្ឋានដូចខាងក្រោម៖

"សិក្ខាកាមចូលរួមមានចាប់ពីយុទ្ធជន រហូតដល់កម្មាភិបាល ប.ក.ក និងអ្នកត្រឡប់មកពីបរទេស ដែលមានចំនួនចាប់ពីរាប់សិបនាក់រហូតដល់រាប់ពាន់នាក់ ដោយពួកគេបានទទួលការបង្រៀនផ្សេងៗ អំពីគោលការណ៍បដិវត្តន៍ សហករណ៍ បច្ចេកទេសកសិកម្ម និងបញ្ហាសេដ្ឋកិច្ច ដោយ ខៀវ សំផន បានបង្រៀនពីវិធីកំណត់អត្តសញ្ញាណខ្មាំង និងស្វែងរកជនក្បត់"[103]។

៥៣. អង្គជំនុំជម្រះបានបញ្ជាក់ថា សាក្សី "រម្លឹកអំពីវគ្គរៀនសូត្រពីរ ធ្វើឡើងនៅឆ្នាំ១៩៧៦ ឬឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ដែលក្នុងវគ្គនោះ ខៀវ សំផន បានបង្រៀនដល់អ្នកចូលរួម ប្រហែល ៤០០ ទៅ ៥០០ នាក់ អំពីទំហំការងារ គឺការផលិតស្រូវឱ្យបានបីតោន ក្នុងមួយហិចតា និងអំពីអ្នកចូលដៃជាមួយវៀតណាម"[104]។ ខុសពីការសន្និដ្ឋានផ្សេងទៀតដែលទាញចេញពីសក្ខីកម្មរបស់ ឯក ហេន អង្គជំនុំជម្រះមានចេតនាធ្វើឱ្យស្រពេចស្រពិល ដោយមិនបញ្ជាក់ឱ្យបានច្បាស់ថា តើលោក ខៀវ សំផន បាននិយាយសម្ដីទាំងនេះ នៅក្នុងវគ្គរៀនសូត្រណាមួយឱ្យប្រាកដ។ ដូច្នេះ អង្គជំនុំជម្រះមិនអាចផ្អែកលើចម្លើយមិនគួរឱ្យជឿជាក់បានរបស់ ឯក ហេន នោះឡើយ។ ក៏ប៉ុន្តែ សេចក្ដីសន្និដ្ឋានផ្នែកអង្គហេតុនេះ គឺជាកត្តាកំណត់ សម្រាប់ "ការវាយតម្លៃលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន"[105] ដោយសារតែអង្គជំនុំជម្រះបានផ្ដល់សារៈសំខាន់ដល់តួនាទីរបស់គាត់។

---

[103] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៦០៧ (ការរកឃើញដែលត្រូវបានជំទាស់តវ៉ានៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ E465/4/1 កថាខណ្ឌ ២៣ កំហុស ៨.៣៧, ៨.៣៨, ៨.៣៩, ៨.៤០ និង ៨.៤១)។

[104] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៦០៧ កំណត់សម្គាល់ជើងទំព័រលេខ ១៩០៤។

[105] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤២០៣។

៥៤. **សេចក្តីសន្និដ្ឋាន៖** ដោយហេតុថានេះជាសាក្សីកម្រមួយដែលអាចឱ្យអង្គជំនុំជម្រះផ្សារភ្ជាប់ លោក ខៀវ សំផន ដោយផ្ទាល់ (ឬដោយប្រយោលច្រើនជាង) ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ អង្គជំនុំជម្រះមានចេតនាមិនអើពើនឹងភាពផ្ទុយគ្នាដ៏សំខាន់ និងបញ្ហានៃការចងចាំ ដែលប៉ះពាល់យ៉ាងច្បាស់ក្រឡែតដល់ភាពអាចជឿជាក់បានរបស់សាក្សី។ កំណត់ហេតុថ្មីរបស់ ឯក ហេន រឹតតែបញ្ជាក់អះអាងពីការសង្កេតឃើញនេះ។ ហេតុនេះហើយទើបមេធាវីការពារក្តីចាំបាច់ត្រូវស្នើសុំតុលាការកំពូល ឱ្យទទួលយកឯកសារនេះជាភ័ស្តុតាងក្នុងបុព្វហេតុនៃបណ្តឹងសាទុក្ខ។ ការរកឃើញផ្នែកអង្គហេតុ ដែលផ្អែកលើចម្លើយរបស់ ឯក ហេន បានដើរតួនាទីយ៉ាងសំខាន់លើការផ្តន្ទាទោសលោក ខៀវ សំផន។ មេធាវីការពារក្តីមានមូលដ្ឋានក្នុងការគិតថា ប្រសិនបើកំណត់ហេតុថ្មីនេះត្រូវបានដាក់ឱ្យពិភាក្សាដេញដោល អង្គជំនុំជម្រះ (ជាអង្គជំនុំជម្រះមួយប្រកបដោយវិចារណញ្ញាណ ទោះជាក្នុងករណីណាក៏ដោយ) ប្រាកដជាប្រកាសសាលក្រមផ្សេងពីនេះ។

## ៣.២. <u>កំណត់ហេតុថ្មីរបស់ ជួន ធី</u>

៥៥. ផ្ទុយទៅវិញ ចំពោះសាក្សី ជួន ធី ចម្លើយដោះបន្ទុករបស់គាត់ត្រូវគេបំភ្លេចចោល។ អតីតប្រធានកងវរសេនាតូចភូមិភាគបូព៌ារូបនេះត្រូវគេស្គាល់ច្បាស់ ក្នុងសំណុំរឿង 00២ ពីព្រោះគាត់បានមកបង្ហាញខ្លួន ទាំងក្នុងសំណុំរឿង 00២/0១[106] និងក្នុងសំណុំរឿង 00២/0២[107] ដោយគាត់បានផ្តល់សក្ខីកម្មអំពីអង្គហេតុជាច្រើនពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍។ ជាពិសេស គាត់បានឆ្លើយថាប្រជាជនមានសេរីភាពក្នុងការរៀបការ ដោយពន្យល់ពីគោលនយោបាយពិតប្រាកដរបស់ ប.ក.ក ពាក់ព័ន្ធនឹងការរៀបការ។ ប៉ុន្តែ អង្គជំនុំជម្រះបានផ្តន្ទាទោសលោក ខៀវ សំផន តាមរយៈការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[108]។

---

[106] ប្រតិចារឹក ថ្ងៃទី២៤ ខែមេសា ឆ្នាំ២0១៣ (សំណុំរឿង 00២/0១) ឯកសារ **E1/183.1**។

[107] ប្រតិចារឹក ថ្ងៃទី២៥-២៦ ខែតុលា ឆ្នាំ២0១៦ (សំណុំរឿង 00២/0២) ឯកសារ **E1/489.1** និងឯកសារ **E1/490.1**។

[108] សាលក្រមសំណុំរឿង 00២/0២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២0១៨ ឯកសារ **E465** កថាខណ្ឌ ៤៣0៨។

៥៦. ជាពិសេស អង្គជំនុំជម្រះបានសន្និដ្ឋានថា មាន "គោលនយោបាយនៃការចេញបទបញ្ជាស្ដីពីការរៀបអាពាហ៍ពិពាហ៍ និងការកសាងគ្រួសារ" ដែលមាន "ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងគោលបំណងរួម" ហើយគោលនយោបាយនេះ "មានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការប្រព្រឹត្តិដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ"[109]។ ដើម្បីសម្រេចគោលដៅនេះ អង្គជំនុំជម្រះបានរកឃើញផ្នែកអង្គហេតុជាច្រើន ដោយភាន់ច្រឡំ ពាក់ព័ន្ធនឹងការចេញបទបញ្ជាស្ដីពីការរៀបអាពាហ៍ពិពាហ៍ ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រកាសពិរុទ្ធភាពលោក ខៀវ សំផន។

៥៧. មេធាវីការពារក្ដីកត់សម្គាល់ឃើញថា អង្គជំនុំជម្រះមានឆន្ទៈបំភ្លេចចោលសក្ខីកម្មដោះបន្ទុករបស់សាក្សី ជួន ធី លើប្រធានបទនេះ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះមិនបានខកខានក្នុងការដកស្រង់ចម្លើយរបស់គាត់នោះទេ ពេលខ្លួនយល់ឃើញថាភ័ស្ដុតាងរបស់គាត់ដាក់បន្ទុក[110]។ ទង្វើនេះស្ដែងឱ្យឃើញថា អង្គជំនុំជម្រះមានភាពលម្អៀងយ៉ាងច្បាស់ក្រឡែត ក្នុងការវាយតម្លៃភ័ស្ដុតាង។ ប៉ុន្តែប្រសិនបើចម្លើយរបស់សាក្សីនេះត្រូវបានយកមកពិចារណាទាំងស្រុង ហើយកំណត់ហេតុថ្មីរបស់គាត់ត្រូវបានដាក់ឱ្យពិភាក្សាដេញដោល អង្គជំនុំជម្រះប្រាកដជាធ្វើសេចក្ដីសន្និដ្ឋានផ្នែកអង្គហេតុជាច្រើនផ្សេងពីនេះ។

## ការរកឃើញពាក់ព័ន្ធនឹងការផ្សំផ្គុំគូស្រករក្នុងវណ្ណៈដូចគ្នា

៥៨. អង្គជំនុំជម្រះសន្និដ្ឋានថា "ប្រវត្តិរូបរបស់បុគ្គលត្រូវបានពិនិត្យ មុននឹងផ្សំផ្គុំពួកគេឱ្យរៀបការ"[111] ហើយ "ជាទូទៅ ប្រជាជនដែលមានប្រវត្តិស្រដៀងគ្នាត្រូវបានផ្សំផ្គុំឱ្យរៀបការជាមួយគ្នា ប្រជាជនមូលដ្ឋានត្រូវបានផ្សំផ្គុំឱ្យរៀបការជាមួយប្រជាជនមូលដ្ឋាន និងមិនឱ្យរៀបការជាមួយប្រជាជនថ្មី

[109] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៤០៦៧។

[110] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៥៦៨ (ស្ដីពីរបាយការណ៍ដែលគាត់ត្រូវផ្ញើទៅថ្នាក់លើ) កថាខណ្ឌ ៣៦៣៦ (ស្ដីពីការគោរពប្រពៃណីខ្មែរក្នុងអាពាហ៍ពិពាហ៍) និងកថាខណ្ឌ ៣៦៣៩ (ស្ដីពីអវត្តមានឪពុកម្ដាយនៅពេលគាត់រៀបអាពាហ៍អាពាហ៍)។

[111] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៥៧៦។

ទេ"[112]។ អង្គជំនុំជម្រះបន្ថែមទៀតថា "ប្រជាជនដែលមានប្រវត្តិផ្សេងគ្នាក៏ត្រូវបានអនុញ្ញាតឲ្យរៀបការជាមួយគ្នាដែរ ប្រសិនបើអាជ្ញាធរយល់ឃើញថាពួកគេជាប្រជាជនល្អ"[113]។

៥៩. ខុសពីការសន្និដ្ឋានទាំងនេះ ដែលត្រូវបានជំទាស់តវ៉ានៅក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ[114] ជួន ធី បានពន្យល់នៅក្នុងកំណត់ហេតុថ្មីថា នៅក្នុងជួរកងទ័ព គេអត់បែងចែកប្រជាជនតាមវណ្ណៈនោះទេ ហើយអ្នកណាក៏ដោយមានសិទ្ធិជ្រើសរើសគូស្រករដែរ[115]។ គាត់បានបន្ថែមទៀតថា នៅក្នុងកងវរសេនាតូចរបស់គាត់ បុរសជ្រើសរើសប្រពន្ធពីក្នុងចំណោមអង្គភាពនារី នៅជិតមូលដ្ឋានរបស់ខ្លួន។ គាត់បាននិយាយថា ក្នុងអង្គភាពនេះ មាននារីជាប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីចម្រុះគ្នា ហើយក្នុងការជ្រើសរើសគូស្រករ អត់មានប្រកាន់ចាស់ថ្មីអីទេ។ បើទាហានពេញចិត្តនឹងនារីណាម្នាក់ជាប្រជាជនថ្មី ក៏រៀបការទៅ[116]។

៦០. ចម្លើយទាំងនេះជំទាស់ដោយផ្ទាល់ទៅនឹងសេចក្តីសន្និដ្ឋានផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះ អំពីការផ្សំផ្គុំគូស្រករ អាស្រ័យតាមវណ្ណៈ។ ថ្វីត្បិតតែសក្ខីកម្មខ្លះ ដែលអង្គជំនុំជម្រះបានដកស្រង់ ស្របតាមការសន្និដ្ឋានរបស់ខ្លួនក៏ពិតមែន ប៉ុន្តែ កំណត់ហេតុរបស់ ជួន ធី ផ្ទុយពីភ័ស្តុតាងដាក់បន្ទុកដែលអង្គជំនុំជម្រះបានទទួលយក។ យោងតាមភ័ស្តុតាងទាំងនេះ អង្គជំនុំជម្រះមិនអាចសន្និដ្ឋានថាមានការអនុវត្តដូចៗគ្នានៅទូទាំងប្រទេស និងមានគោលនយោបាយថ្នាក់ជាតិដែលបក្សបានអនុម័ត ដូចខ្លួនបានរៀបរាប់នោះទេ[117]។

## ការរកឃើញពាក់ព័ន្ធនឹងទាហានពិការ

---

[112] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៥៨០។

[113] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៥៨០។

[114] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ២៩ កំហុស ១៤.៣៥ និង ១៤.៣៦។

[115] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ធី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ **E319/71.2.4** ស./ឆ. ១២៣ និង ១២៤។

[116] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ធី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ **E319/71.2.4** ស./ឆ. ១២៩ ដល់ ១៣១។

[117] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៥៤៣។

៦១. ចំពោះទាហានពិការ មេធាវីការពារក្តីជំទាស់នឹងការសន្និដ្ឋានរបស់អង្គជំនុំជម្រះថា "សក្ខីកម្មទាំងនេះបង្ហាញថា ការរៀបការរវាងកងទ័ពពិការ ដែលត្រូវបានចាត់ទុកថាជាវរជនសង្គ្រាម និងជាជនបដិវត្តន៍ដែលគេជឿទុកចិត្ត ជាមួយនឹងនារីក្មេងៗ ដែលត្រូវបានជ្រើសរើសពីប្រជាជនមូលដ្ឋាន ត្រូវបានរៀបចំឡើង តាមគោលនយោបាយដែលគាំទ្រដោយថ្នាក់ខ្ពស់បំផុតនៃ ប.ក.ក។ ផ្អែកលើគុណតម្លៃមនោគមន៍វិជ្ជានេះ នារីៗត្រូវបានគេរំពឹងថានឹងបូជាខ្លួនឯង ដើម្បីបុព្វហេតុស្នេហាជាតិ និងដើម្បីជាផលប្រយោជន៍បដិវត្តន៍"[118]។

៦២. ថ្វីត្បិតតែចម្លើយរបស់ ជួន ធី បញ្ជាក់អះអាងថា ការរៀបការត្រូវបានរៀបចំឡើងសម្រាប់ទាហានពិការ ហើយនារីនៅសម័យនោះត្រូវមានការលះបង់ខ្ពស់ក៏ដោយ ក៏គាត់បានឆ្លើយច្បាស់ថានារីមានសិទ្ធិបដិសេធ ដោយគ្មានផលវិបាកអ្វីទេ[119]។ ដូច្នេះ សក្ខីកម្មរបស់គាត់រំលេចឲ្យឃើញជាថ្មីម្តងទៀតថា ប្រជាជនមិនត្រូវគេបង្ខំឲ្យរៀបការនោះទេ និងយ៉ាងហោចណាស់ វាក៏មិនមែនជាគោលនយោបាយដែលអនុម័តដោយ "ថ្នាក់ខ្ពស់បំផុតនៃ ប.ក.ក" ដូចការសន្និដ្ឋានខុសរបស់អង្គជំនុំជម្រះនោះដែរ[120]។

## ការរកឃើញពាក់ព័ន្ធនឹងការអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍

៦៣. ក្នុងសំអាងហេតុនៃសាលក្រម អង្គជំនុំជម្រះបានរកឃើញផ្នែកអង្គហេតុជាច្រើន ពាក់ព័ន្ធនឹងការអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះបានសន្និដ្ឋានថា អាជ្ញាធរថ្នាក់លើចេញសេចក្តីណែនាំដល់ថ្នាក់ក្រោមឲ្យផ្សំផ្គុំគូស្រករ និងរៀបចំបញ្ជីឈ្មោះឲ្យកម្មាភិបាលថ្នាក់លើឯកភាព[121]។

---

[118] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៥៩០ (ការរកឃើញដែលត្រូវបានជំទាស់តវ៉ានៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ២៩ កំហុស ១៤.៣៩ និង ១៤.៤១)។

[119] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ធី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ **E319/71.2.4** ស./ឆ. ១៩១ ដល់ ១៩៨។

[120] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៦៧០។

[121] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៥៩៥-៣៥៩៨, ៣៦០៨ (ការ

ការរៀបអាពាហ៍ពិពាហ៍ទាំងអស់ មិនថាស្នើឡើងដោយសាមីខ្លួន ឬអាជ្ញាធរទេ ចាំបាច់ត្រូវមានការអនុញ្ញាតពីថ្នាក់លើ[122]។

៦៤. ជួន ធី បានផ្តល់សក្ខីកម្មយ៉ាងវែងអន្លាយអំពីរបៀបនៃការរៀបអាពាហ៍ពិពាហ៍ នៅក្នុងអង្គភាពរបស់គាត់។ ប៉ុន្តែ ចៅក្រមបានបំភ្លេចចោលសក្ខីកម្មរបស់គាត់ ដែលមិនស៊ីគ្នានឹងអង្គហេតុតាមការចង់បានរបស់ខ្លួន។ ទោះជាយ៉ាងណា គាត់គឺជាសាក្សីកម្រម្នាក់ ដែលមេធាវីការពារក្តីបានស្នើសុំឱ្យកោះហៅមកបង្ហាញខ្លួន[123]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះមិនខ្វីយកភ្នែកមើលសក្ខីកម្មរបស់គាត់ផង។ យ៉ាងណាមិញ គាត់បានពន្យល់ច្បាស់ក្នុងសវនាការថា ក្នុងករណីអាជ្ញាធរស្នើឱ្យបុគ្គលណាម្នាក់រៀបការ បុគ្គលនោះមានសិទ្ធិប្រកែក ដោយគ្មានផលវិបាកអ្វីទេ[124]។ ចម្លើយនេះត្រូវបានបញ្ជាក់អះអាងនៅក្នុងកំណត់ហេតុថ្មីរបស់គាត់[125] ដែលគួរណាធ្វើឱ្យអង្គជំនុំជម្រះសន្និដ្ឋានខុសពីមុន រួមទាំងការសន្និដ្ឋានអំពីការយល់ព្រមពីសាមីខ្លួនផងដែរ។

**ការរកឃើញពាក់ព័ន្ធនឹងការជូនដំណឹង និងការយល់ព្រមពីសាមីខ្លួន**

៦៥. ក្នុងសំអាងហេតុនៃសាលក្រម អង្គជំនុំជម្រះបានសន្និដ្ឋានថា បុគ្គល "ជាធម្មតា មិនបានទទួលការពិភាក្សាអំពីការរៀបការរបស់ខ្លួនទេ ហើយបានទទួលការជូនដំណឹងតែបន្តិចបន្តួច ឬអត់បានទទួល

---

រកឃើញដែលត្រូវបានជំទាស់តវ៉ានៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ២៩ កំហុស ១៤.៤៤ និង ១៤.៤៥)។

[122] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៦០២ (ការរកឃើញដែលត្រូវបានជំទាស់តវ៉ានៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ២៩ កំហុស ១៤.៤៥)។

[123] សាក្សី និងអ្នកជំនាញដែលស្នើឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ ឯកសារ **E305/5** ជាមួយនឹងឧបសម្ព័ន្ធ E305/5.1 ទំព័រ ១ និង E305/5.2 ទំព័រ ១។

[124] ប្រតិចារឹក ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ (សំណុំរឿង ០០២/០២) ឯកសារ **E1/490.1** ពីម៉ោង [09:10:57] ដល់ [09:14:35] និងពីម៉ោង [09:18:57] ដល់ [09:23:05]។

[125] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ធី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ **E319/71.2.4** ស./ឆ. ១៩៣ ដល់ ១៩៨។

ដំណឹងទាល់តែសោះថាពួកគេនឹងត្រូវរៀបការនោះ"[126]។ ពាក់ព័ន្ធនឹងការយល់ព្រម អង្គជំនុំជម្រះបានសន្និដ្ឋានថា "ពួកគេមិនអាចបដិសេធការរៀបការ ដោយមិនទទួលរងបញ្ហានោះឡើយ។ អង្គជំនុំជម្រះក៏ជឿជាក់ផងដែរថា បរិយាកាសបង្ខិតបង្ខំនៅទូទាំងប្រទេស ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ គឺថាមិនអាចមានការយល់ព្រមពិតប្រាកដឡើយ ហេតុដូច្នេះ បុគ្គលទាំងនោះមិនមានជម្រើសអ្វីផ្សេងក្រៅពីការគោរពតាម និងរៀបការតាមការអនុវត្តដោយមានលក្ខណៈបង្ខំ ដែលកើតចេញពីបទបញ្ជារបស់ ប.ក.ក ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍នោះទេ"[127]។ អង្គជំនុំជម្រះបានសន្និដ្ឋានក្នុងន័យដូចគ្នានេះថា កម្មាភិបាលខ្លះអាចជ្រើសរើសប្រពន្ធបាន ឯនារីត្រូវគេបង្ខំ[128]។

៦៦. ដើម្បីឈានដល់ការរកឃើញទាំងនេះ ដែលត្រូវបានជំទាស់តវ៉ាផងដែរ[129] អង្គជំនុំជម្រះបានដកស្រង់ចម្លើយរបស់សាក្សីមួយចំនួន ដែលបានអះអាងថា ពួកគេត្រូវបានរៀបការដោយបង្ខំ ឬដោយគ្មានការយល់ព្រម[130]។ ប៉ុន្តែ អង្គជំនុំជម្រះបានបង្ខំចិត្តលើកឡើងផងដែរនូវសាក្សីខ្លះទៀតជាអតីតកម្មាភិបាល ប.ក.ក ដែលបានឆ្លើយថា យោងតាមគោលនយោបាយផ្លូវការរបស់ ប.ក.ក និងក្នុងការអនុវត្តជាក់ស្តែង គេតម្រូវឱ្យភាគីទាំងពីរយល់ព្រមរៀបការ ហើយអ្នកប្រកែកមិនមានបញ្ហាអ្វីកើតឡើងនោះទេ[131]។ អង្គជំនុំជម្រះមិនបានទាញផលវិបាកចេញពីសក្ខីកម្មទាំងនេះទេ។ ទោះជាយ៉ាងណា គោលជំហរនេះស្របគ្នានឹងសក្ខីកម្មរបស់ ជួន ធី ដែលអង្គជំនុំជម្រះមានចេតនាបំភ្លេចចោល និងស្របគ្នានឹងចម្លើយនៅក្នុងកំណត់ហេតុចុងក្រោយរបស់គាត់។ ជាក់ស្តែង សាក្សីតែងតែឆ្លើយរហូតថា ការរៀបការមិនត្រូវបានបង្ខិតបង្ខំទេ នៅក្នុងអង្គភាពរបស់គាត់ គឺប្តីប្រពន្ធរៀបការ តាមការស្ម័គ្រចិត្ត[132]។ គាត់ថែមទាំងបានលើកឡើងអំពីការរៀបការរបស់គាត់ទៀតផង ដែលត្រូវបានរៀបចំឡើង តាមការព្រមព្រៀងពីសាមីខ្លួនទាំងសងខាង[133]។

---

[126] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៦១៦។

[127] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៦២៦។

[128] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៥៩១ និង ៣៦២៣។

[129] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ E465/4/1 កថាខណ្ឌ ២៩ កំហុស ១៤.៤២, ១៤.៤៩, ១៤.៥៣ និង ១៤.៥៤។

[130] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៦១៩ ដល់ ៣៦២៤។

[131] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៦១៧។

[132] ប្រតិចារឹក ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ (សំណុំរឿង ០០២/០១) ឯកសារ **E1/183.1** ពីម៉ោង [09:57:15] ដល់ម៉ោង [10:03:25], ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ (សំណុំរឿង ០០២/០២) ឯកសារ **E1/489.1** ម៉ោង [15:57:29],

៦៧. ចំពោះការណែនាំវិញ ជួន ធី បានបញ្ជាក់ថា គាត់មិនធ្លាប់ឮថាត្រូវបង្ខំប្រជាជនឲ្យរៀបការទេ[134]។ ផ្ទុយទៅវិញ គាត់បានឆ្លើយថា ពេលប្រជុំ ក្នុងខែមិថុនា ឆ្នាំ១៩៧៨ នៅខេត្តកំពង់ឆ្នាំង គាត់បានឮ ប៉ុល ពត ពន្យល់ថា ត្រូវរៀបចំការរៀបការ ប៉ុន្តែ កុំបង្ខំ គឺត្រូវឲ្យមានការយល់ព្រមពីសាមីខ្លួន[135]។ ចម្លើយនេះក៏ស៊ីសង្វាក់គ្នាផងដែរនឹងភ័ស្តុតាងផ្សេងទៀត ដូចជា គោលការណ៍ទាំងពីររបស់បក្សស្តីពីការកសាងគ្រួសារ ដែលចុះផ្សាយក្នុងទស្សនាវដ្តី *យុវជន និងយុវនារីបដិវត្ត* ខែតុលា ឆ្នាំ១៩៧៨៖

> "ទី ១ សាមីខ្លួនទាំងសងខាងយល់ព្រម។ ទី ២ សមូហភាពយល់ព្រម ក៏ជាការស្រេចទៅហើយ។ តើមានហេតុផលអីនាំឲ្យយើងប៉ះពាល់សីលធម៌នារីបុរស"[136]។

៦៨. គោលការណ៍ទាំងពីរនេះកើតចេញពីសីលធម៌ ១២ ប្រការ ដែលបក្សបានតាក់តែងឡើង តាំងពីឆ្នាំ ១៩៦៨ គឺ "កុំប្រព្រឹត្តអ្វីដែលល្មើសនឹងស្ត្រីភេទឲ្យសោះ"[137]។

៦៩. ជាថ្មីម្តងទៀត ភ័ស្តុតាងទាំងនេះផ្ទុយគ្នាទាំងស្រុងនឹងការសន្និដ្ឋានជារួមរបស់អង្គជំនុំជម្រះអំពីការជូនដំណឹង និងការយល់ព្រមពីសាមីខ្លួន និងគោលនយោបាយ ប.ក.ក ស្តីពីការចេញបទបញ្ជាលើ

---

ប្រតិចារឹក ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ (សំណុំរឿង ០០២/០២) ឯកសារ **E1/490.1** ពីម៉ោង [09:06:12] ដល់ម៉ោង [09:13:46], កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ធី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ **E319/71.2.4** ស./ឆ. ៣៣, ៣៤, ១០៤ ដល់ ១០៩, ១១៨, ១២៣, ១២៤, ១៣០ ដល់ ១៣៣។

[133] ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ (សំណុំរឿង ០០២/០២) ឯកសារ **E1/489.1** ពីម៉ោង [15:55:03] ដល់ម៉ោង [15:57:29] និងក្រោយម៉ោង [15:57:29]។

[134] ប្រតិចារឹក ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ (សំណុំរឿង ០០២/០២) ឯកសារ **E1/490.1** ពីម៉ោង [09:11:40] ដល់ម៉ោង [09:113:46]។

[135] ប្រតិចារឹក ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ (សំណុំរឿង ០០២/០២) ឯកសារ **E1/490.1** ពីម៉ោង [09:35:21] ដល់ម៉ោង [09:36:03] ដែលអះអាងបញ្ជាក់លើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរបស់ខ្លួនគាត់ ធ្វើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E3/10713** ស/ឆ. ២៨ និង ២៩។ សូមមើលផងដែរ កំណត់ហេតុថ្មីនៃការស្តាប់ចម្លើយសាក្សី ជួន ធី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ **E319/71.2.4** ស./ឆ. ៣៣។

[136] ទស្សនាវដ្តី យុវជន និងយុវនារីបដិវត្ត ខែតុលា ឆ្នាំ១៩៧៨ ឯកសារ **E3/765**, ERN 00376493។

[137] ទស្សនាវដ្តី យុវជន និងយុវនារីបដិវត្ត ខែតុលា ឆ្នាំ១៩៧៨ ឯកសារ **E3/765**, ERN 00376492។

ការរៀបអាពាហ៍ពិពាហ៍។ ក្នុងការពិចារណាលើការផ្តន្ទាទោស អង្គជំនុំជម្រះទទួលយកតែសក្ខីកម្មដាក់បន្ទុក និងច្រានចោលសក្ខីកម្មដោះបន្ទុកជាច្រើន ក្រោមលេសបោកបញ្ឆោតថាអតីតកម្មាភិបាលទាំងនោះមាន "ទំនោរចង់បន្ថយការទទួលខុសត្រូវផ្ទាល់ខ្លួនពួកគេតែប៉ុណ្ណោះ"[138]។ ក៏ប៉ុន្តែ សេចក្តីសន្និដ្ឋានសមហេតុផល និងអាចជឿជាក់បានមួយទៀតគឺថា កម្មាភិបាលជាបុគ្គលស័ក្តិសមបំផុតសម្រាប់ផ្តល់សក្ខីកម្មអំពីគោលនយោបាយ ប.ក.ក។ សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះមានការភាន់ច្រឡំ ពីព្រោះថាវាមិនត្រឹមតែផ្ទុយនឹងសក្ខីកម្មទាំងនេះទេ ថែមទាំងផ្ទុយនឹងអត្ថបទផ្លូវការ និងឯកសារឃោសនារបស់ ប.ក.ក ទៀតផង[139]។

៧០. ពិតមែនតែសាក្សីបានឆ្លើយថា ពួកគេបានរៀបការក្រោមការបង្ខិតបង្ខំក៏ដោយ ក៏អង្គជំនុំជម្រះគួរណាតែបែងចែងឱ្យដាច់ រវាងគោលនយោបាយផ្លូវការរបស់ ប.ក.ក ដែលតម្រូវឱ្យមានការព្រមព្រៀងជាមុនពីអនាគតគូស្វាមី-ភរិយា និងការអនុវត្តជាក់ស្តែង ដែលមិនឆ្លុះបញ្ចាំងអំពីអត្ថិភាពនៃគោលនយោបាយថ្នាក់ជាតិស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បើពិនិត្យលើសក្ខីកម្មទាំងមូល។ ដូច្នេះ សក្ខីកម្មរបស់ ជួន ធី ដែលស្ថិតនៅក្នុងន័យនេះ គួរត្រូវពិចារណា ដោយសត្យានុម័តិ។

**ការរកឃើញពាក់ព័ន្ធនឹងការរួមដំណេក**

៧១. អង្គជំនុំជម្រះបានជឿជាក់ថា ក្រោយពីរៀបការរួច "ជាទូទៅ ប្តីប្រពន្ធថ្មីត្រូវបានគេតាមដាន ដើម្បីធ្វើឱ្យប្រាកដថាពួកគេបានរួមដំណេកក្នុងការរៀបការរបស់ពួកគេ" និងមានបរិយាកាសបង្ខិតបង្ខំធ្វើឱ្យពួកគេរួមភេទ ដោយភ័យខ្លាចការសងសឹក[140]។ អង្គជំនុំជម្រះបានពិនិត្យមើលតែសក្ខីកម្មដាក់បន្ទុក និងបំភ្លេចចោលសក្ខីកម្មរបស់ ជួន ធី ដែលបញ្ជាក់ថា ក្នុងអង្គភាពរបស់គាត់ "ពេលដែល

---

[138] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៦២៣។

[139] គ្រប់ចំណុចទាំងអស់នេះនឹងមានអធិប្បាយនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី។

[140] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៦៤៤ ដល់កថាខណ្ឌ ៣៦៤៧ (ការរកឃើញដែលត្រូវបានជំទាស់តវ៉ានៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ២៩ កំហុស ១៤.៥៩ និង ១៤.៦០)។

រៀបចំហើយ មិនឲ្យទៅតាមដានរឿងដំណោកអីជាមួយគ្នា គឺអត់ដែលឮ"។ គាត់បានបន្ថែមទៀតថា៖ "អត់មានដែលឮអ្នកខាងលើឲ្យតាមដានទេ ខ្ញុំអត់ដែលក្ដាប់បាន អត់ដែលឮសោះ"[141]។

៧២. ក្នុងកំណត់ហេតុថ្មីរបស់គាត់ ពេលគេសួរលើប្រធានបទនេះ សាក្សីបានឆ្លើយថា ក្រោយពីរៀបការរួច គាត់រួមរស់ជាមួយប្រពន្ធបានកន្លះខែ ហើយគ្មានអ្នកណាមកសួរថាតើគាត់ចុះសម្រុងគ្នា ឬអត់ទេ។ គាត់បានពន្យល់ទៀតថា ក្រោយមក គាត់ និងប្រពន្ធគាត់ ត្រឡប់ទៅធ្វើការវិញ តាមអង្គភាពរៀងៗខ្លួន ហើយពួកគាត់ជួបគ្នា បី ទៅបួនថ្ងៃម្ដង ពីព្រោះការងារមិនអនុញ្ញាតឲ្យជួបគ្នាញឹកញាប់ជាងនេះបាន[142]។

៧៣. **សេចក្ដីសន្និដ្ឋាន៖** កំណត់ហេតុថ្មីរបស់ ជួន ធី ដែលបញ្ជាក់អះអាង និងបំពេញបន្ថែមលើចម្លើយពីមុនរបស់គាត់ ចោទជាបញ្ហាដល់ការរកឃើញផ្នែកអង្គហេតុមួយចំនួនធំរបស់អង្គជំនុំជម្រះ។ ប៉ុន្តែការរកឃើញទាំងនេះមានផលប៉ះពាល់ធ្ងន់ធ្ងរ នៅក្នុងការសម្រេចរបស់អង្គជំនុំជម្រះលើពិរុទ្ធភាពរបស់លោក ខៀវ សំផន។ ជាក់ស្តែង អង្គជំនុំជម្រះបានប្រើប្រាស់ការរកឃើញទាំងនេះ ដើម្បីបង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការប្រព្រឹត្តិដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ពិតជាបានកើតឡើង[143]។ អង្គជំនុំជម្រះក៏បានប្រើប្រាស់ការរកឃើញផ្នែកអង្គហេតុទាំងនេះ ដើម្បីបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយស្ដីពីការចេញបទបញ្ជាលើការរៀបអាពាហ៍ពិពាហ៍[144] និងជាពិសេស ដើម្បីកំណត់អំពីចរិតឧក្រិដ្ឋនៃគោលនយោបាយនេះ ដែលអាចឲ្យអង្គជំនុំជម្រះដាក់បញ្ចូលឧក្រិដ្ឋកម្មទាំងនេះក្នុងគោលបំណងរួម[145] សម្រាប់បម្រើឲ្យការផ្ដន្ទាទោសលោក ខៀវ សំផន ពីបទចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម។

---

[141] ប្រតិចារឹក ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ (សំណុំរឿង 00២/0២) ឯកសារ **E1/490.1** ពីម៉ោង [09:13:46] ដល់ម៉ោង [09:15:47]។

[142] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជួន ធី ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ **E319/71.2.4** ស./ឆ. ១១៧ ដល់ ១២០។

[143] សាលក្រមសំណុំរឿង 00២/0២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៦៩០ ដល់ ៣៧00។

[144] សាលក្រមសំណុំរឿង 00២/0២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៣៥៣៩ ដល់ ៣៥៦៣។

[145] សាលក្រមសំណុំរឿង 00២/0២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ **E465** កថាខណ្ឌ ៤០៦៤ ដល់ ៤០៦៧។

## ៤. ភស្តុតាងដែលស្នើសុំមិនស្ថិតនៅក្រោមមូលហេតុទូទៅនៃភាពមិនអាចទទួលយកបានទេ

៧៤. យោងតាមវិធាន ១០៨(៧) នៃវិធានផ្ទៃក្នុង សំណើនេះស្ថិតនៅក្រោមបទប្បញ្ញត្តិនៃវិធាន ៨៧(៣) ដែលចែងថា៖

"អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភ័ស្តុតាង បើយល់ឃើញថា៖ (ក) មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា (ខ) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ (គ) មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង (ឃ) ច្បាប់មិនអនុញ្ញាត ឬ (ង) មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍"។

៧៥. កំណត់ហេតុរបស់ ឯក ហេន និង ជួន ធី ដែលត្រូវបានស្នើសុំឲ្យទទួលយកជាភ័ស្តុតាង មានភាពជាប់ពាក់ព័ន្ធយ៉ាងខ្លាំង ដោយសារតែអង្គជំនុំជម្រះបានប្រើសាក្សីទាំងនេះជាសាក្សីដាក់បន្ទុក ក្នុងសំអាងហេតុនៃសាលក្រម។ ចំពោះសាក្សីដែលបានផ្តល់សក្ខីកម្មជាធម្មតា ចំពោះមុខអង្គជំនុំជម្រះ ចម្លើយពីមុនៗរបស់ពួកគេអាចឲ្យវិនិច្ឆ័យអំពីភាពអាចជឿជាក់បាន និងភាពមិនសមហេតុផលនៃសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះ ដើម្បីផ្តន្ទាទោសលោក ខៀវ សំផន។ ខ្សែអាត់ថតសំឡេងនៃការស្តាប់ចម្លើយ ក៏អាចមានផលប៉ះពាល់លើភាពអាចជឿជាក់បាននៃចម្លើយរបស់សាក្សីផងដែរ។ ក្រៅពីនេះទៀត កំណត់ហេតុមិនមានភាពជាន់គ្នានោះទេ។ ជាថ្មីម្តងទៀត ឯក ហេន បានផ្តល់ចម្លើយថ្មីខុសពីចម្លើយពីមុនរបស់គាត់។ ជួន ធី បានផ្តល់ព័ត៌មានលម្អិតសំខាន់ជាងអំពីការចេញបទបញ្ជាស្តីពីការរៀបអាពាហ៍ពិពាហ៍ និងបាននិយាយពីប្រធានបទថ្មីៗ ដូចជាការរៀបការជាមួយជនពិការ។

៧៦. កំណត់ហេតុរបស់ ឯក ហេន និង ជួន ធី អាចរកបានរួចទៅហើយ ហើយភាគីអាចចូលមើលបានតាំងពីពេលសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យដាក់បង្ហាញ។ ខ្សែអាត់ថតសំឡេងអាចទទួលបានភ្លាម ប្រសិនបើសហព្រះរាជអាជ្ញាខ្មែរផ្តល់ជូន។ កំណត់ហេតុទាំងនេះត្រូវបានធ្វើឡើងនៅក្នុងក្របខ័ណ្ឌតុលាការ ដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានធ្វើសម្បថ ហើយតាមការពិនិត្យបឋម អាចជឿទុកចិត្តបាន និងសមស្របសម្រាប់បញ្ជាក់អង្គហេតុ

ដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង។ កំណត់ហេតុទាំងនេះមិនប្រឡូកប្រឡាក់ដោយការធ្វើទារុណកម្ម ឬកាលៈទេសៈដែលច្បាប់ហាមឃាត់ នោះទេ។

៧៧. ភាគីគួរណាតែមានលទ្ធភាពពិភាក្សាដេញដោលកំណត់ហេតុទាំងនេះ នៅចំពោះមុខអង្គជំនុំជម្រះ ពេលអង្គជំនុំជម្រះដឹងថាមានកំណត់ហេតុទាំងនេះ នៅក្នុងដំណាក់កាលពិភាក្សាសម្រេច។ ដូច្នេះ មេធាវីការពារក្តីមានបំណងចង់ជួសជុលភាពអយុត្តិធម៌នេះ និងអាចពិភាក្សាដេញដោលនៅក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ដោយសារតែខ្លួនមិនអាចធ្វើបាននៅសាលាដំបូង។ សំណើនេះមានភាពស្របច្បាប់ មានមូលដ្ឋានត្រឹមត្រូវ និងដើម្បីជាប្រយោជន៍យុត្តិធម៌។

៧៨. **<u>អាស្រ័យហេតុនេះ</u>** មេធាវីការពារក្តីស្នើសុំតុលាការកំពូលមេត្តា**ទទួលយកជាភស្តុតាង**នូវឯកសារ **E319/71.2.7** និង **E319/71.2.4** ព្រមទាំងខ្សែអាត់ថតសំឡេងពាក់ព័ន្ធ ចាប់ពីពេលសហព្រះរាជអាជ្ញាដាក់បង្ហាញ តាមការបង្គាប់ពីតុលាការកំពូល។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br><br>ទីក្រុងប៉ារីស | |